ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

# ទស្សនាវដ្ដី គ្រូបង្រៀន

១៧

តុលា.វិច្ឆិកា.ធ្នូ ២០០៣



# វិចារណកថា

មនុស្សជាធនធានមួយសំខាន់សំរាប់ធ្វើអោយពិភពលោកមានការកែប្រែមុខមាត់ ព្រោះគេមានពន្លករូបកាយ បញ្ញា ស្មារតី សញ្ចេតនាតាំងពីកំនើត ។ ប៉ុន្តែសម្ប័ទ[១] ទាំងនោះរីកលូតលាស់អាស្រ័យទៅលើថ្នាលមជ្ឈដ្ឋានរស់នៅ អប់រំ បទពិសោធផ្ទាល់ខ្លួនដែលបានជួយថែបំប៉នបណ្តុះបណ្តាលកសាងវាជាជំហាន១ ដើម្បីអោយក្លាយជាមនុស្សពេញលេញប្រកបដោយភាពសុខដុមរមនារវាងកាយសម្បទា បញ្ញាសម្បទា ពលកម្មសម្បទា សីលសម្បទា និង សោភ័ណសម្បទា ។

ដូចនេះ ដើម្បីសំរេចគោលដៅនោះ មនុស្សជាតិបានខិតខំកសាងជំនាន់របស់ខ្លួន ហើយកសាងមុខវិជ្ជាឯកទេសមួយ គឺការអប់រំ(គរុកោសល្យ)ដែលប្រទេសទាំងអស់លើលោកត្រូវកំនត់តួនាទី និង ទីតាំងវាអោយបានសមស្របជាក់លាក់ ។

ការងារអប់រំនេះ ត្រូវចំណុះទៅនឹងមុខព្រួញសំខាន់១ដូចតទៅ ÷

- វត្ថុអប់រំ (សិស្ស)
- មជ្ឈដ្ឋាន
- អ្នកអប់រំ (ឪពុកម្តាយ-គ្រូ)
- គោលដៅអប់រំ
- បច្ចេកទេសអប់រំ (គរុកោសល្យ)

មុខព្រួញទាំងនេះ មានចំណងទាក់ទងគ្នាជាអន្តរកម្ម ។ នេះជាគំនូសបំព្រួញមួយដែលវិទ្យាសាស្ត្រមានអាយុប្រមាណ៦០ឆ្នាំ ស៊ីបែរណេទិច(Cybernétique)បានលើកអំពីអន្តរកម្មនោះ ÷




(១)(សំ.សម្ប័ទ.បា.សម្បទា) : ការសមប្រកប, ការដល់ព្រម

### គណៈកម្មការរៀបរៀង និង និពន្ធ

- លោក កែវ យ៉ារ
- លោក ដុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណាវុណ
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី នន់ សុគុំ
- លោក ប៉ែន សារុន
- សមាជិក សមាជិកា ស.ប.ស.ខ

### គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ សិរី
- លោកបណ្ឌិត អ៊ុម កុច
- លោក ស៊ិន ស៊ីម
- លោក សួង សារុន
- លោក ស៊ុង វ៉ាន់ថន

### វិចិត្រករ

លោក ប៉ាន់ ត្រា

### ការីកុំព្យូទ័រ

ក. ម៉ៃ សូនី

### ក្របខាងក្រៅ:

- ពីមុខ : ក្របខាងមុខនៃទស្សនាវដ្ដីទាំង ១៦
- ពីក្រោយ : ស្ត្រីខ្មែរកាលពី ១០០ឆ្នាំមុន

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **ទស្សនវិជ្ជាទូទៅ** | |
| ៤ | ព្រះពុទ្ធសាសនា និង ការអប់រំ | ៣ |
| ៥ | សុជីវធម៌ | ៥ |
| ៦ | អច្ឆរិយវត្ថុក្នុងលោក ឬបេតិកភណ្ឌពិភពលោក | ៨ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៧ | តើត្រូវបង្រៀនដោយប្រើវិធីណា? | ១២ |
| ៨ | ដំណើរការនៃញាណវិច្ឆតាខាងបញ្ញា | ១៥ |
| | **វិទ្យាសាស្ត្រ និង ពត៌មានបច្ចេកវិទ្យា** | |
| ៨ | ថ្មបំបែក | ២០ |
| ៩ | ម៉ាស៊ីនគិតលេខអេឡិចត្រូនិចជាអ្វី? | ២២ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ១០ | លំហាត់បុរេសិក្សា( ត) | ២៥ |
| ១១ | ភាសា : ឈ្មោះឃុំ ស្រុក ខេត្តស្វាយរៀង | ២៧ |
| ១២ | ប្រវត្តិវិទ្យា : ការតាំងរាជធានីនៅឧដុង្គ និង ទំនាស់ផ្ទៃក្នុង | ២៩ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ( ត) | ៣២ |
| ១៤ | ភូមិវិទ្យា : គូរផែនទីប្រទេសកម្ពុជា | ៣៥ |
| ១៥ | គណិតវិទ្យា : វិធីបូក ដក | ៣៦ |
| ១៦ | គណិតវិទ្យា : ត្រីកោណ | ៣៩ |
| | **នាទីកំនាព្យ និង កំសាន្ត** | |
| ១៧ | ការអប់រំនៅមត្តេយ្យសិក្សា | ៤០ |
| ១៨ | ច្បាប់ត្រីនេតិ | ៤១ |
| ១៩ | បទដ្ឋាននៃខ្នាតក្រដាស | ៤២ |
| | **វេទិកាស្វែរិន** | |
| ២០ | ព្យាង្គតំរូត | ៤៣ |
| ២១ | ភូមិអន្លង់រមៀត | ៤៥ |
| | **ពត៌មាន** | |
| ២៣ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេ ? | ៤៧ |
| ២៤ | ពុទ្ធសាសនបណ្ឌិត្យ | ៤៩ |
| ២៥ | ស្ត្រីក្នុងវិស័យច្បាប់ | ៥១ |

(1) $E_1$ : ឯកសារផ្ដល់ពត៌មានពីសភាពនៃមជ្ឈដ្ឋាន

(2) $E_2$ : ឯកសារស្រាវជ្រាវពីសភាពនៃសិស្ស

ដូចនេះ ការអប់រំត្រូវប្រព្រឹត្តទៅនៅក្នុងសង្គម ដោយសារសង្គម ដើម្បីសង្គម ដែលជាទស្សនៈផ្ទុយនឹងលោក រូស្សូ (J.J.Rousseau) ដោយលោកចង់អោយការអប់រំត្រូវប្រព្រឹត្តទៅនៅដាច់ឆ្ងាយពីសង្គម ដើម្បីកុំអោយសិស្ស ឆ្លងតាមអំពើអសកម្មនៅក្នុងសង្គមទីមួយៗ ។

ដោយមានទស្សនៈបដិបក្ខបែបនេះ តើគ្រូត្រូវដើរតួជាអ្វីខ្លះ ដើម្បីសំរេចឧត្ដមគតិទាំងពីរខាងលើអោយបាន នោះ ?

- ការបង្រៀនល្អជាប្រការមួយដ៏សំខាន់ ទោះការបង្រៀនអ្វីដែលអាក្រក់បំផុតក៏ដោយក៏ត្រូវតែបង្រៀន អោយបានល្អិតល្អន់ អោយយល់ស៊ីជំរៅអត្ថន័យ ខ្លឹមសារដែលជាក្រិត្យក្រមរបស់វា ដូចជាលើកយក មេរៀន "អំពើពុករលួយ" ជាដើម ។
- ព្រមជាមួយនោះ គ្រូត្រូវលើកយកផលប៉ះពាល់ផ្សេងៗបណ្ដាលមកពីអំពើនោះធ្វើអោយខ្លួនគេចេះគ្រប់ គ្រងខ្លួនគេអោយបាន កុំអោយលូកលាន់ចូលក្នុងអំពើនោះ ពោលគឺគ្រូជាអ្នកអប់រំផងដែរ ។
- ទន្ទឹមនឹងនេះ គ្រូក៏ត្រូវវង់ចាំពត៌មានពីលទ្ធផលនៃការបណ្ដុះបណ្ដាលរបស់ខ្លួន ថាតើគោលបំណង និង បច្ចេកទេសគរុកោសល្យដែលខ្លួនបានគ្រោងទុកបាននាំដល់គោលដៅដែររឺទេ ។ ដូចនេះ គ្រូក៏ត្រូវជាអ្នក គ្រប់គ្រងល្អមួយរូបទៀត ។

ជារួម អ្នកគ្រូ លោកគ្រូ ត្រូវធ្វើជាគំរូប្រកបដោយជំហារបីយ៉ាងខាងលើ : បង្រៀនល្អ អប់រំល្អ គ្រប់គ្រងល្អ ។

**គណៈកម្មាធិការនាយក**

| |
|---|
| **គ្រូគប្បីដាក់ខ្លួនជាគំរូ ជាអ្នកដឹកនាំ ជាទីប្រឹក្សារបស់សិស្ស**<br>**ពុំមែនជាចៅហ្វាយផ្ដាច់ការលើសិស្សឡើយ ។**<br>ខេមរយានកម្ម |

* *La cybernétique telle qu'elle est*




## ពុទ្ធសាសនា និង ការអប់រំ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រាទី ៤៣ ចែងថា : "...ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ប្រជាពលរដ្ឋខ្មែរចំនួនច្រើនលើសលប់ សុទ្ធតែបានប្រកាស និង ទទួលស្គាល់ខ្លួនឯងថា ជាពុទ្ធសាសនិកជន ពោលគឺជាអ្នកជឿ និង ប្រតិបត្តិតាមព្រះពុទ្ធសាសនា ។ ព្រះធម៌ទាំងឡាយដែលជាពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធសុទ្ធសឹងជាកំលាំងចលករដ៏មានប្រសិទ្ធភាពក្នុងការបណ្តុះមេត្តា ករុណា កំចាត់បង់អំពើហឹង្សា និង កិលេសគ្រប់យ៉ាង ហើយនាំមកនូវសុវត្ថិភាព ស្ថេរភាព សន្តិភាព និង សមភាព ។

មូលហេតុយ៉ាងណាបានជាសង្គមខ្មែរយើងដែលជាសង្គមព្រះពុទ្ធសាសនា នៅតែមានការបៀតបៀនគ្នា ធ្វើទុក្ខបុកម្នេញគ្នា ធ្វើអាក្រក់រកគ្នារហូតដល់វាយដំច្រំធាក់ កាប់សំលាប់គ្នាដូចដែលយើងបានប្រទះឃើញរឿយៗនៅតាមខ្ទង់ទំព័រកាសែតសឹងតែរាល់ថ្ងៃបែបនេះ ?

គ្រាន់តែប៉ះគ្នាបន្តិចបន្តួច គ្រាន់តែគេមើលមុខចំ គ្រាន់តែគេជាន់ជើងជាអចេតនា ដោយសារកន្លែងចង្អៀត ឬសាចទឹកប្រឡាក់បន្តិចបន្តួច-ល- ក៏បង្កបានទៅជាទំនាស់តឹងមាត់តឹងកធំដុំ ខ្លាំងក្លា ធ្ងន់ធ្ងរ ជួនកាលដល់ស្លាប់រស់ទៀតក៏សឹងមាន ។

យើងសួរថា តើការអប់រំរបស់ព្រះពុទ្ធសាសនាដល់ពុទ្ធមាមកជនខ្មែររបៀបណា បានជាផលសំរេចពុំបានសមប្រកបតាមព្រះបំណងរបស់ព្រះពុទ្ធអង្គបែបនេះ ។

មុននឹងតាំងសំនួរនេះឡើង យើងគួរដកថយមកពិចារណាពីអំពើពុទ្ធសាសនិកជនខ្មែរយើងបន្តិចសិន ។

ដូចបានពោលខាងលើរួចមកហើយ ប្រជាពលរដ្ឋកម្ពុជា៩៥%កាន់សាសនាព្រះពុទ្ធ ។ ប៉ុន្តែនៅពេលដែលមានគេសួរចង់ដឹង ចង់យល់ អំពីខ្លឹមសារ ឬអត្ថរសនៃជំនឿក្នុងសាសនារបស់ខ្លួនយ៉ាងណានោះ គេច្រើនតែជួបការលំបាក ដោយពុំអាចឆ្លើយតបសំនួរ ឬនិយាយប្រាប់គេ អំពីទស្សនៈសំខាន់ៗ ខ្លីៗបានឡើយ ។ ត្រង់នេះហើយសបញ្ជាក់ថា យើងជាពុទ្ធសាសនិកជន ប៉ុន្តែយើងមិនទាន់បានយល់ជ្រួតជ្រាបអត្ថរសពុទ្ធោវាទអោយបានច្បាស់លាស់ និង ត្រឹមត្រូវនៅឡើយ ។

ព្រះពុទ្ធអង្គទ្រង់មានព្រះបន្ទូលថា : "ឯហិ បស្សិកោ" មានន័យថា "ចូលមក ហើយមើល" ។ ព្រះអង្គមិនបាន

មានព្រះបន្ទូលថា : "ចូលមក ហើយជឿ" នោះទេ ។ ព្រះពុទ្ធមិនចង់បានសាវ័កទាំងឡាយប្រកបដោយសទ្ធាងងឹតងងល់ឡើយ ព្រះអង្គចង់បានមនុស្សចេះត្រិះរិះ និង ចេះស្វែងយល់ ។ ព្រះពុទ្ធសាសនា គឺជាមាគ៌ាមួយដ៏ប្រសើរសំរាប់ការរស់នៅ ដែលនៅលើមាគ៌ានោះគ្របដណ្តប់លើសលប់ជាងគេដោយមនុស្សនិយម សមភាព យុត្តិធម៌ និង សន្តិភាព ។ អំពើសងសឹក អវិភាព ការផ្តន្ទា និង គំនុំគុំគួន គឺជាសភាវៈខាងក្រៅពីព្រះធម៌ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ការអប់រំមនុស្សដោយព្រះធម៌រមែងធ្វើអោយមនុស្សមានជីវិតល្អបរិសុទ្ធ មានឥស្សរភាពលើតណ្ហា មានសេចក្តីសុខក្នុងតួជីវិតរបស់ខ្លួន។ មនុស្សកើតមកហើយត្រូវមានការសិក្សា ព្រោះមនុស្សជាសត្វដែលត្រូវសិក្សា ឬជាសត្វដែលត្រូវហ្វឹកហាត់អប់រំ ។ បើមិនហ្វឹកហាត់សិក្សាអប់រំទេនោះ មនុស្សមិនអាចល្អទៅបានឡើយ ហើយជីវិតដ៏ប្រសើរដែលបុណ្យបានតាក់តែងមកក៏ត្រូវអស់ទៅវិញដោយឥតប្រយោជន៍ ។ នេះជារឿងធម្មជាតិរបស់មនុស្ស ។ មនុស្សផ្សេងអំពីសត្វតិរច្ឆាន គឺនៅត្រង់មនុស្សជាសត្វពិសេសអាចហ្វឹកហាត់អប់រំអោយមានការចំរើនដោយខ្លួនឯង ។ គុណធម៌ដែលមានក្នុងមនុស្ស មិនមានគុណធម៌ណាមួយដែលកើតមានឯងៗនោះឡើយ គឺសុទ្ធតែជាលទ្ធផលនៃការអប់រំចំរើនទាំងអស់ ។

ដោយសារហេតុផលដូចបានវិភាគជំរាបជូនខាងលើនេះហើយទើបយើងបានយល់ និង មើលឃើញថា ព្រះធម៌ដែលជាដំបូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ ពុំទាន់បានផ្សព្វផ្សាយជ្រួតជ្រាបចូលទៅក្នុងស្រទាប់មហាជនខ្មែរតាមការសិក្សាស្រាវជ្រាវ ការត្រិះរិះពិចារណា ស្វែងយល់ និង ប្រតិបត្តិតាមដោយជឿជាក់នោះនៅឡើយទេ ។ កាន់ព្រះពុទ្ធសាសនាដោយគ្រាន់តែកាន់តាម ជឿតាម សូត្រតាម ប្រតិបត្តិតាមតៗគ្នាពីជំនាន់មួយទៅមួយពុំបានឃើញច្បាស់ យល់ច្បាស់ ជឿច្បាស់ នោះព្រះធម៌ក៏ពុំបានជ្រាបចូលជ្រៅទៅក្នុងសន្តានចិត្តប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ហើយក៏ពុំទាន់បានក្លាយទៅជាទំលាប់ល្អ ជាផ្នត់គំនិតប្រចាំថ្ងៃ ឬជាបែបបទនៃមាគ៌ាជីវិតដ៏ប្រសើររបស់ពុទ្ធសាសនិកជនខ្មែរនៅឡើយ ។

ដូចនេះដើម្បីសំរេចគោលដៅក្នុងការកសាងជីវិតតាមព្រះពុទ្ធសាសនា គួរគប្បីអប់រំខ្លួនចាប់តាំងពីបឋមវ័យបច្ឆិមវ័យរហូតដល់មជ្ឈិមវ័យអោយបានពេញមួយជីវិតតរៀងទៅ ហើយត្រូវតែបកប្រែព្រះធម៌អោយបានទូលំទូលាយ ។

លោក : **យស់ អ៊ាង**

**"អត្តាហិ អត្តនោ នាថោ"**

**(ខ្លួនទីពឹងខ្លួន)**

ពុទ្ធសុភាសិត

# សុជីវធម៌

សុជីវធម៌ជាពាក្យសមាសផ្សំឡើងដោយ សុ + ជីវ + ធម៌ មានន័យថាការរស់នៅដោយល្អ គឺចំនេះសណ្ដាប់ធ្នាប់ ការដឹងប្រមាណគួរសមក្នុងកិច្ចការប្រាស្រ័យជាមួយនឹងអ្នកដទៃ ។

ចំនេះនេះត្រូវបានធ្វើការហាត់សមដល់មនុស្សតាំងពីគេចេញផុតពីផ្ទៃមាតាមកម្ល៉េះ ។ឆ្មបទាំងឡាយ តែងបានយកចិត្តទុកដាក់ទទួលកុមារពីឧទរមាតាគេដោយស្មារតីថ្នាក់ថ្នម ផ្ចិតទឹកសំអាតសរីរាង្គកាយដោយទឹកក្ដៅឧណ្ហ១ ដើម្បីសំរបសំរួលបរិយាកាសផ្ទេរពីក្នុងផ្ទៃមាតាមកកាន់បរិយាកាសជាលំហទូលាយ ដោយមានការរុំដណ្ដប់អោយកក់ក្ដៅ ព្រមទាំងបីថ្នមដោយទឹកមុខញញឹមទៅរកទារកជាទេវបុត្រមួយរូបស្អាតស្អំជាទីបំផុត និង មានឫទ្ធិអំណាច (ពូកពស់អាសិរពិសលូនទៅសុខមិនរួច កាលបើជួបប្រទះនារីមានផ្ទៃពោះ) ។ ក្នុងន័យនេះផងដែរ មានកើតជំនឿថា គេត្រូវតែជ្រើសរើសឆ្មបដែលមានឫកពាត្រឹមត្រូវមានឫទ្ធិអំណាច ដើម្បីអោយទារកទទួលមរតកនេះ ។

ការហាត់សមបំពាក់សុជីវធម៌នេះ មានទំហំធំធេងពុំមាននរណាធ្លាប់កត់ត្រា រឺប្រមាណបាន ពិបាកនឹងកំនត់ពេលវេលា ខ្លឹមសារ និង ទីកន្លែងសំរាប់ការហ្វឹកហាត់នេះ ។

បុព្វបុរសយើងបានកំនត់ការអប់រំនេះថា ត្រូវតែប្រព្រឹត្តទៅមុនកុមារកើតរាប់ជំនាន់ យ៉ាងហោចណាស់ត្រឹមពីម្ដាយឪពុកដែរ "ទុកដាក់កូនចៅ មើលផៅសន្ដាន", "ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់", "ដឹងឆ្លើយដ្បិតដង កូនសោតវែងឆ្លង ដ្បិតតែឪពុក" ... ។ ឯណាប៉ូឡេអុងវិញមានទស្សនៈថា "ការអប់រំកុមារត្រូវធ្វើតាំងពី ២០ ឆ្នាំមុនគេកើត" ហើយលេនីន : ដាំដើមឈើដប់ឆ្នាំអាចទទួលផ្លែ តែកសាងមនុស្សត្រូវធ្វើរយៈពេល ១០០ ឆ្នាំ ។

ពេលនេះ យើងសូមមិនលើកការអប់រំដែលមានកម្មវិធីរៀបរយនោះទេ ដែលមានតាំងពីទារកដ្ឋាន បឋមសិក្សា ហើយនៅមធ្យមសិក្សាគេបានរៀបចំជាមុខវិជ្ជាមួយដូចជាគណិតវិទ្យា រូបវិទ្យា... មានគ្រូទទួលបន្ទុក ដោយឡែកអាចថាគ្រូឯកទេសដូចមុខវិជ្ជាដទៃកំនត់ចូលក្នុងកម្មវិធីសិក្សាក្នុងមួយអាទិត្យពីរម៉ោង ។ ក្នុងកាលៈទេសៈខ្លះគេយកមុខវិជ្ជានេះជាបទដ្ឋានពិន្ទុឈានមុខ ។ ឧទាហរណ៍ : គេត្រូវកែមុខវិជ្ជានេះមុនគេដោយកំនត់យកមធ្យមពិន្ទុជាដើម ។ ក្នុងករណីមុខវិជ្ជានេះមិនបានមធ្យមពិន្ទុទេ នោះគេមិនពិនិត្យមុខវិជ្ជាដទៃទៀតទេ ។ តែទីនេះយើងសូមលើកយកការអប់រំក្រៅប្រព័ន្ធមកពិចារណា ។ ការអប់រំនេះ បានចាប់ផ្ដើមដំណាលគ្នានឹងការដែលកុមារចាប់ចេះឃ្លាន ហើយមាតាបិតាជាគ្រូទី ១ ជាព្រះទី ១ ។ ដូចនេះមាតាបិតាត្រូវមានចំនេះនេះ ត្រូវតែបានរៀនសូត្រពីមជ្ឈដ្ឋានសង្គម សាលារៀនអោយបានច្បាស់លាស់ទៅលើខ្លឹមសារមួយជាកំនត់ ជាក់ស្ដែង ÷

- ការទៀងទាត់ : មាតាបិតាមិនត្រូវទុកបណ្ដោយអោយទារកយំទារបៅ រឺក៏អោយទារកបៅទៅតាមការយំរបស់វាទេ។ គេត្រូវកំនត់ពេលវេលាច្បាស់លាស់ក្នុង១ថ្ងៃត្រូវអោយបៅប៉ុន្មានដង នៅម៉ោងណា។ ធ្វើយ៉ាងនេះ ទារកមិនយំទារបៅទៀតទេ ។ ក្នុងករណីមានការយំនោះ យើងអាចកំនត់បានថាកុមារមានវិបត្តិអ្វីមួយ។

- សេចក្ដីអង់អាច : ការភ័យខ្លាច ការព្រួយបារម្ភហួសហេតុរបស់មាតាបិតាដែលទំលាប់តែងក្រុងកូនអោបកូនក្នុងគ្រែជាមួយគ្នា ជាប្រការមួយធ្វើអោយកូនកើតស្មារតីរារែកមិនក្លាហាន តែយើងមិនមែនបោះបង់ទារកអោយឯកោនោះទេ យើងត្រូវឃ្លាំមើលជាប្រចាំដោយកុំអោយទារកដឹងខ្លួន ។
- ការគួរសម

  ការហ្វឹកសីលធម៌នេះ បានចាប់ដំនើរព្រមជាមួយនឹងការបំបៅដំបូងដល់ទារក ÷
  - មាតាទាំងឡាយមុននឹងបំបៅកូន តែងសំដែងអាកប្បកិរិយាអោយកុមារីករាយនឹងទទួលចំនីដែលគេបានអោយនោះ ដូចជាធ្វើអោយសើច ថ្វីបើទារកមិនទាន់មានសញ្ញាណនេះក្ដី ។
  - ទាក់ទងនឹងការប្រាស្រ័យជាមួយអ្នកដទៃ មាតាតែងធ្វើអោយទារកធ្វើមុខរីករាយទៅកាន់អ្នកនេះ អ្នកនោះ ឧទាហរណ៍ : ញញឹមដាក់បងមួយ ដាក់មីង ដាក់ពូ យាយ តា ... ។
  - នៅពេលទារកចេះប្រើកាយវិការ គេបង្រៀនបន្ថែមអោយចេះសំពះ "ពន" មួយ (វន្ទា) ... ។

សរុបសេចក្ដីទៅ មាតាបិតាបានធ្វើការសមអំពីសុជីវធម៌នេះច្រើនបែប ច្រើនយ៉ាងដែលពិបាកនឹងចងក្រងជាកម្មវិធីឯកភាព រឺបញ្ជាក់ខ្លឹមសារអោយបានច្បាស់លាស់ ព្រោះអាស្រ័យទៅលើលទ្ធភាពសមត្ថភាពមាតាបិតា ។ បើនិយាយដោយសាមញ្ញត្រូវសមតាំងពីបៅ ដេក ចុះដើរ អង្គុយ... ។ មាតាបិតាទាំងឡាយបានអនុវត្តបែបដោយភាវគតិ ។ បើពុំដូចនោះទេ ទារកនឹងក្លាយទៅជាមនុស្សគ្មានសណ្ដាប់ធ្នាប់ ។ ជាក់ស្ដែង ក្មេងដែលគេរកឃើញរស់នៅជាមួយសត្វ វាគ្រងគ្រាប់សត្វទាំងអស់ វាមិនចេះទាំងសំរបសំរួលជាមនុស្សបានទៀតផង ។ ក្នុងន័យនេះហើយដែលគេតែងលើកឡើងថាមនុស្សកើតពីរដង : កើតពីឧទរមាតា និងពីការអប់រំ "...ព្រះជនកសោតណា បង្កើតអាត្មាអោយមានសរីលផង...។ រីគ្រូបាធ្យាយ អាចអោយពណ្ណរាយ មានរូបរស្មី... (ច្បាប់ក្រម)" ។

ដូចនេះ ក្នុងករណីមាតាបិតាមានលទ្ធភាពសមត្ថភាពផ្ទាល់ខ្លួន រឺអោយអ្នកដទៃជួយហ្វឹកហាត់បានតិចតួចនោះ បុត្រធីតាក៏ទទួលការយល់ដឹងបានតិចតួចដែរ មិនឆ្ងាយពីមាតាបិតាឡើយ ។

ប៉ុន្តែនៅពេលមានវត្តអារាម កុលបុត្រខ្មែរមួយចំនួនបានបន្តការសិក្សានៅក្នុងសំណាក់ព្រះសង្ឃ ។ វត្តអារាមដើរតួសំខាន់ណាស់ក្នុងការអប់រំសុជីវធម៌នេះ ។ ជាក់ស្ដែង ព្រះចៅអធិការវត្តនីមួយៗបានធ្វើការសមឥរិយាបថយ៉ាងតឹងរឹង និង ដោយយកចិត្តទុកដាក់បំផុត នៅពេលបុណ្យទាន នៅពេលមានប្រជុំធំៗ ។ នៅពេលនោះចៅអធិការតែងនិមន្តទៅកាន់សាលាឆាន់ក្រោយពីឆាន់ចង្ហាន់ព្រឹករួច រឺព្រះអង្គគង់នៅកន្លែងនោះរហូតតាំងពីឆាន់ព្រឹករួចដើម្បី ÷

- ទាក់ទងជាមួយឧបាសក ឧបាសិកា
- ត្រួតពិនិត្យរាល់សកម្មភាពរបស់ភិក្ខុសាមណេរ និង កូនសេក្ខ(១) ខាងក្រោម ÷
  - ពេលវេលានិមន្តមកកាន់សាលាឆាន់
  - ឥរិយានិមន្ត ដើរឆ្លងកាត់ឧបាសក ឧបាសិកាដែលកំពុងអង្គុយ

(១) កូនសេក្ខ រឺសេក្ខលោក : អ្នកដែលនៅក្នុងកំពុងសិក្សា-អ្នករៀន

- បែបបទកាន់ស្លាបព្រាឆាន់
- ការឆាន់ រឺបរិភោគអាហារ
- ការក្រោកឡើងត្រលប់នៅកុដិវិញ-ល- ។

**ក្នុងករណី :**

- ការនិមន្តឃឹតយ៉ាវ រឺបើមានអង្គណានិមន្តក្រោយគេ រឺសិស្សមកយឺតជាងគេ ។
- ការឆ្លងកាត់ឧបាសក ឧបាសិកា មិនចេះអោនលំទោន
- មុនឆាន់អាហារ រឺបរិភោគអាហារមិនបានសំពះចំពោះចង្ហាន់ រឺអាហារ ។
- ការឆាន់អាហារឮសូរស្លាបព្រា រឺសល់ចង្ហាន់ រឺម្ហូបអាហារនៅក្នុងចានទំរ រឺចោលឆ្អឹងសំនល់ផ្ដេសផ្ដាស រឺមានជ្រុះចង្ហាន់ រឺម្ហូបអាហារនៅលើកន្ទេល
- ការឆាន់អាហារ រឺបរិភោគលាន់ឮ
- ការហារព្រះឱស្ឋ រឺហារមាត់ធំសំរាប់ឆាន់ រឺបរិភោគ
- ការឆាន់អាហាររហ័សជាងគេ មិនមើលគេឯង មិនចាំអ្នកយឺត រឺការឆាន់យឺតពេកមិនមើលគេឯង ( អង្គខ្លះឆាន់យឺត ជាទូទៅឆាន់មិនឆ្អែតទេ តែឃើញភាគច្រើនឆាន់ហើយត្រូវសំរបនឹងគេ)
- ការក្រោកចេញពីកន្លែងមិនបានព្រម១គ្នា ...

សុទ្ធតែត្រូវបានលើកចូលជារបៀបវារៈប្រជុំជីវភាពនៅពេលរសៀល រឺក្រោយពេលបុណ្យ ។ នរណាប្រព្រឹត្តខុសឆ្គងក្នុងគន្លងណាមួយត្រូវតែទទួលទណ្ឌកម្ម : អាចត្រូវវាពាត់ រឺអោយបោសសំអាតទីអារាម រឺរែកទឹកដាក់ពាងតែម្នាក់ឯង-ល- ។

ទាំងនេះជារឿងកំប៉ិកកំប៉ុកក៏ពិតមែន តែវាមានតំលៃធំធេងណាស់ ។ សព្វថ្ងៃក្នុងពិធីជប់លៀងជាកិត្តិយសអ្វីមួយ រឺធ្វើការអ្វីមួយ ឥរិយាបថខាងលើទាំងប៉ុន្មាន ត្រូវតែប្រព្រឹត្តទៅអោយបានសមរម្យជាទីបំផុត ។ តំលៃសុជីវធម៌ក្នុងអង្គប្រជុំ រឺក្នុងពិធីជប់លៀងនេះមានអត្ថិភាពជារៀងរហូតមក ហើយនិងមានតំលៃតទៅទៀត ។ តែចំពោះមុខនេះ ការអនុវត្តមិនបានដូចបំនងឡើយ : គេមិនដែលឃើញភ្ញៀវអញ្ជើញចូលរួមប្រជុំសាធារណៈ រួមអាពាហ៍ពិពាហ៍តាមម៉ោងកំនត់ឡើយ ។ ដូចនេះដើម្បីសំរេចតាមបំនង គេច្រើននិយមបញ្ជាក់ម៉ោងមុន ១ ម៉ោង រឺកន្លះម៉ោងជាដើម ។ តែប្រការនេះ ប្រសិនជាក្នុងជួរកងទ័ព ក្នុងពេលបំពេញបេសកម្មវិញនោះច្បាស់ជាត្រូវទទួលបរាជ័យជាមិនខាន ។

តែទោះជាយ៉ាងណា ក្នុងស្ថានភាពណាក៏ដោយ អង្គគ្រូបង្រៀនយើងពុំដែលធ្វើអោយសិស្សរង់ចាំ រឺធ្វើអោយខូចខាតពេលវេលាដ៏មានតំលៃឡើយ ព្រោះពេលវេលាកន្លងទៅពុំអាចវិលត្រលប់វិញទេ ។

**កែវ យ៉ារ**

# អច្ឆរិយវត្ថុក្នុងលោក ឬបេតិកភណ្ឌពិភពលោក

អច្ឆរិយវត្ថុទាំងប្រាំពីរនៃសកលលោកសម័យបុរាណ (les sept merveilles du monde antique) នោះ គឺពុំមែនបញ្ជីឈ្មោះអច្ឆរិយវត្ថុនាសម័យបច្ចុប្បន្ននេះទេ ។ ជនជាតិក្រិចបានរៀបចំបញ្ជីឈ្មោះវត្ថុស្ថាដែដ៏សំបើម មហិមាបានចំនួនប្រាំពីរ ហើយដែលទាំងអស់នោះស្ថិតនៅតំបន់ខាងកើតសមុទ្រមេឌីទែរ៉ាណេ តាំងពីជាង២០០០ឆ្នាំ មុនគ.សមកម្ល៉េះ ហើយបានលើកថាជាអច្ឆរិយវត្ថុទាំងប្រាំពីរនៃសកលលោក (សូមអានទស្សនាវដ្ដីលេខ ១៣ ទំព័រ ១០) ។ មកដល់បច្ចុប្បន្នកាលនេះ អច្ឆរិយវត្ថុទាំង ៧ នោះបានរលាយរលត់បាត់ស្រមោលអស់ទៅហើយ នៅសល់តែពីរ៉ាមីតនៃប្រទេសអេហ្ស៊ីបមួយប៉ុណ្ណោះ ។

ដូច្នេះគួរកុំពោលទៀតថា ប្រាសាទ អង្គរវត្តជាអច្ឆរិយវត្ថុទី ៧ នៃសកលលោក ដែលនាំអោយកូនចៅយើង ជំនាន់ក្រោយ យល់ច្រឡំខុសពីការពិត ។ ប៉ុន្តែតំបន់អង្គរ បានបញ្ចូលទៅជាបេតិកភណ្ឌពិភពលោក (Patrimoine mondial) កាលពីឆ្នាំ១៩៩៣ រួចហើយ ។

តើអ្វីទៅជាបេតិកភណ្ឌពិភព លោក ?

បេតិកភណ្ឌ ត្រូវនឹងពាក្យ បារាំងថា Patrimoine មានន័យ ថា ទ្រព្យសម្បត្តិ ឬ កេរ្តិ៍មរតក ដែលមានជាប់តមកពីខាងឪពុក ។ ប៉ុន្តែមកដល់ស.វទី ១៩ ន័យខាង លើនេះ ត្រូវបានភ្ជាប់ទៅនឹងសញ្ញាណ បេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម ហើយ បានក្លាយទៅជាកេរ្តិ៍មរតករួមនៃក្រុម មនុស្ស ឬសមូហភាពមួយ។ ក្រោយ មក អ្នកស្នេហាសិល្បៈ ស្ថាបត្យកម្ម និង ប្រវត្តិសាស្ត្រទាំងឡាយបានជួប ប្រជុំគ្នានៅក្រុងអាថែនប្រទេសក្រិច នាឆ្នាំ ១៩៣១ ដើម្បីពិគ្រោះ ពិចារណារួមគ្នា អំពីបញ្ហាបេតិក ភណ្ឌវប្បធម៌របស់ មនុស្សជាតិ ។

### អច្ឆរិយវត្ថុទាំងប្រាំពីរនៃសកលលោកសម័យបុរាណ



នៅឆ្នាំ ១៩៤៥ ក្រោយពីសង្គ្រាមលោកលើកទី ២ ត្រូវបានបញ្ចប់ មានប្រទេសចំនួន ៣៧ បានចុះហត្ថលេខាលើកតិកាសញ្ញាមួយបង្កើតអង្គការសហប្រជាជាតិ (UN) ដែលក្នុងនោះមានបង្កើតអង្គការយូណេស្កូផងដែរ គឺ អង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌នៃសហប្រជាជាតិ (UNESCO : United Nations Educational, Scientific and Cultural Organization)។ តាមរយៈការប្រឹងប្រែងរបស់យូណេស្កូ និង ដោយមើលឃើញទំហំនៃការខូចខាតវត្ថុសិល្បៈ ទីក្រុងបូរាណ និង ប្រាសាទនានាជាច្រើនដោយសារតែសង្គ្រាមនោះ គេក៏បានខិតខំរិះរកវិធានការ និងមធ្យោបាយដោះស្រាយការថែរក្សាវត្ថុបុរាណទាំងឡាយអោយបាននៅស្ថិតស្ថេរគង់វង្សជានិច្ចតទៅ។ មកដល់ឆ្នាំ ១៩៥៤ នាទីក្រុងឡាអេ (La Haye) គេបានអនុម័តលើអនុសញ្ញាមួយ ស្ដីពីការការពារសម្បត្តិវប្បធម៌ក្នុងករណីមានអាវុធសង្គ្រាម ។

នេះជាកិច្ចព្រមព្រៀងជាអន្តរជាតិដំបូងបង្អស់ ដែលផ្ដោតដល់កិច្ចការពារបេតិកភណ្ឌវប្បធម៌ ។ គំនិតថែរក្សាការពារបេតិកភណ្ឌ ចេះតែរីកចំរើនជាលំដាប់ ។ បេតិកភណ្ឌពិភពលោកមិនស្ថិតនៅត្រឹមតែសម្បត្តិវប្បធម៌ប៉ុណ្ណោះទេ គឺត្រូវថែរក្សាការពារផងដែរនូវសម្បត្តិធម្មជាតិផ្សេងទៀត រួមមានរមណីយដ្ឋានធម្មជាតិច្រើនប្រភេទ ដែនជំរកសត្វកំរៗ រុក្ខជាតិប្លែកៗ តំបន់ទេសភាពប្រណីត តំបន់មានកំណកំណើតជីវសាស្ត្រចំរុះ រូបសាស្ត្រ ឧទ្យានជាតិ សម្បត្តិធនធានលិចកប់នៅបាតសមុទ្រ.... ហើយបច្ចុប្បន្ននេះ គេគិតគូរទៅដល់បេតិកភណ្ឌអរូបី (patrimoine immatériel) ថែមទៀត ។

គំនិតទាំងអស់ខាងលើ បានក្លាយជាឧបករណ៍ដ៏សំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ឈានទៅដល់ការរៀបចំអនុសញ្ញាបេតិកភណ្ឌពិភពលោកដែលត្រូវបានប្រទេសជាង២០ចុះហត្ថលេខា នៅទីក្រុងប៉ារីសនាឆ្នាំ ១៩៧២ ក្នុងមហាសន្និបាតយូណេស្កូលើកទី ១៧ ។ មកដល់ឆ្នាំ ២០០២ ជាឆ្នាំខួបទី ៣០ មានប្រទេសហត្ថលេខីកើនចំនួនឡើងដល់ ១៧៥ ប្រទេស ។ ដូចនេះយើងឃើញថា ពិភពលោកទាំងមូលបានយកចិត្តទុកដាក់ដល់កិច្ចថែរក្សាការពារបេតិកភណ្ឌដែលជាសម្បត្តិរបស់មនុស្សជាតិ ។ នៅក្នុងកិច្ចថែរក្សាការពារនេះទៀត ក៏គេឃើញច្បាស់ថាបេតិកភណ្ឌមិនមែនរងគ្រោះ និង ខូចខាតដោយសារតែសង្គ្រាមនោះទេ ។ នៅមានកត្តាផ្សេងទៀត ដែលអាចមានផលប៉ះពាល់ និង បង្កគ្រោះថ្នាក់បានដែរដូចជា ការបំពុលបរិយាកាសដោយភាពកខ្វក់ ការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍន៍រហ័សខ្វះការពិចារណាល្អិតល្អន់ នគរោបនីយកម្មលឿនហួសហេតុ ទេសចរណ៍ប្រមូលផ្តុំ។ល។ និយាយជារួម សឹងតែគ្រប់ទិដ្ឋភាពនៃពិភពលោកសម័យទំនើបយើងនេះ បើសិនខ្វះការវិភាគស្រាវជ្រាវពិចារណាគិតគូរអោយបានច្បាស់លាស់គ្រប់ជ្រុងជ្រោយទេនោះ ប្រាកដជាអាចបង្កគ្រោះថ្នាក់ដល់បេតិកភណ្ឌបាន ។

អនុសញ្ញាឆ្នាំ ១៩៧២ ដំណើរការដោយមហាសន្និបាតនៃរដ្ឋជាសមាជិកទាំងឡាយ ២ ឆ្នាំម្ដង និង ដោយមានមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ការិយាល័យបេតិកភណ្ឌពិភពលោក និង មូលនិធិបេតិកភណ្ឌពិភពលោក ដើម្បីកំណត់លក្ខខណ្ឌនៃការសុំចូលជាបេតិកភណ្ឌពិភពលោក ទទួលសិក្សាគំរោងសុំជំនួយ ពិនិត្យរបាយការណ៍អំពីសភាពនៃរមណីយដ្ឋាននានា តាមដានរៀបចំការប្រជុំសិក្ខាសាលា និង ផ្សព្វផ្សាយបញ្ជីឈ្មោះរមណីយដ្ឋាន និង រមណីយដ្ឋានដែលរងគ្រោះថ្នាក់។ល។ មកដល់បច្ចុប្បន្ននេះ បញ្ជីឈ្មោះ

រមណីយដ្ឋានបេតិកភណ្ឌពិភពលោក ឬថាបញ្ជីឈ្មោះ"អច្ឆរិយវត្ថុក្នុងលោក" រាប់ឃើញចំនួនទាំងអស់ ៧៣០ រមណីយដ្ឋានវប្បធម៌ និង ធម្មជាតិដែលមានរាយនៅក្នុងប្រទេស ១២៥ ក្នុងចំនួននោះមាន :

- រមណីយដ្ឋានវប្បធម៌ : ៥៦៣
- រមណីយដ្ឋានធម្មជាតិ : ១៤៤
- រមណីយដ្ឋានចំរុះ : ២៣

ដូចនេះរមណីយដ្ឋានអង្គរ ពុំមែនជាអច្ឆរិយវត្ថុទី ៧ ក្នុងលោកនោះទេ ។ រមណីយដ្ឋានជាបេតិកភណ្ឌពិភពលោកពុំត្រូវបានធ្វើចំណាត់ថ្នាក់ឡើយ គ្រាន់តែចុះឈ្មោះចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប៉ុណ្ណោះ ។

តើសំរាប់អ្វីទៅដែលបានចុះឈ្មោះចូលក្នុងបញ្ជីដ៏ល្បីល្បាញនោះ ?

ការងារនេះបានផ្តល់ដល់រមណីយដ្ឋាននូវកិត្តិសព្ទកាន់តែល្បីល្បាញថែមទៀត ដោយបដិរូប "បេតិកភណ្ឌពិភពលោក"(១) បានទាក់ទាញអារម្មណ៍យ៉ាងខ្លាំង ។ ម្យ៉ាងទៀត សម្បត្តិដែលបានចុះឈ្មោះរួចហើយ ត្រូវបានស្ថិតក្រោមកិច្ចការពារជាអន្តរជាតិ ។ ហើយបើរដ្ឋដែលមានសម្បត្តិទាំងនោះស្ថិតនៅ ត្រូវការលើកសំណើសុំជំនួយផ្សេងៗ ដើម្បីជួយថែរក្សា ឬការពារពីគ្រោះធម្មជាតិនោះនឹងមានការចូលរួមជួយ អាចជាគ្រឿងផ្គត់ផ្គង់ ជាអ្នកបច្ចេកទេស អ្នកជំនាញការ ធ្វើសមិទ្ធកម្មសិក្សាជាថវិកាជំនួយ ។ល។

នៅឆ្នាំ ១៩៩៥ ក្នុងសន្និសីទការទូតនៅទីក្រុងរ៉ូមដែលមានតំណាង ៧០ ប្រទេសចូលរួមបានអនុម័តលើគំរោងអនុសញ្ញាអ៊ុយនីឌ្រ័រ (la Convention d'UNIDROIT) ស្តីពីសម្បត្តិវប្បធម៌ដែលត្រូវគេលួច ឬត្រូវគេធ្វើនិហរណកម្មខុសច្បាប់ ដែលព្រះរាជាណាចក្រកម្ពុជាយើងក៏ជាប្រទេសហត្ថលេខីមួយដែរ ។ ប៉ុន្តែដោយមានការយឺតយ៉ាវក្នុងការអោយសច្ចាប័ន ការរៀបចំលិខិតូបករណ៍ផ្សេងៗទៅដាក់ល់ទុកនៅក្នុងទីក្រុងរ៉ូម និង បញ្ហាមួយចំនួនទៀត អនុសញ្ញាអ៊ុយនីឌ្រ័រទើបតែបានចូលជាធរមាននៅកម្ពុជាក្នុងពេលថ្មីៗនេះ ។ តាមខ្លឹមសារអ៊ុយនីឌ្រ័រ យើងអាចលើកសំណើទាមទារអោយសង ឬបញ្ជូនមកវិញនូវសម្បត្តិវប្បធម៌ដែលបានលើកឡើងដោយប្រទេសហត្ថលេខី ។ នេះគឺជាវិធានការមួយដ៏សំខាន់ក្នុងការទប់ស្កាត់ការលួច និង ការជួញដូរវត្ថុបុរាណនានា ។

PATRIMONIO MUNDIAL · WORLD HERITAGE · PATRIMOINE MONDIAL

Dessiné par Michel Olyff, l'emblème du patrimoine mondial symbolise les biens culturels et naturels: le carré central est une forme géométrique typiquement créée par l'homme, le cercle représente la nature. L'emblème est rond comme la Terre, il symbolise aussi la protection.

(១) បដិរូប "បេតិកភណ្ឌពិភពលោក" គូរដោយលោក Michel Olyff ជានិមិត្តរូបនៃសម្បត្តិវប្បធម៌ និងធម្មជាតិតាងដោយការេនៅចំកណ្តាលរាងធរណីមាត្រដែលបង្កើតឡើងតួយ៉ាងដោយមនុស្ស ហើយរង្វង់មូលតំណាងអោយធម្មជាតិ ។ បដិរូបដែលមានរាងមូលដូចផែនដីនោះ ក៏តំណាងអោយការការពារផងដែរ ។

ក្នុងន័យទាំងអស់ខាងលើនេះ យើងឃើញថាសម្បត្តិវប្បធម៌ និង សម្បត្តិធម្មជាតិទាំងឡាយពុំមែនមានតំលៃសំរាប់តែប្រជាជនជាម្ចាស់ស្រុកប៉ុណ្ណោះទេ តែសំរាប់មនុស្សជាតិទាំងអស់នៅក្នុងលោក ។ ដូចឃ្លាមួយក្នុងបុព្វកថានៃអនុសញ្ញាឆ្នាំ ១៩៧២ បញ្ជាក់ច្បាស់ថា : "ការធ្វើអោយខូចខាត ឬបាត់បង់នូវសម្បត្តិនៃបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ បង្កឱ្យមានភាពថមថយខ្សត់ខ្សោយយ៉ាងអាក្រក់បំផុតដល់បេតិកភណ្ឌរបស់ប្រជាពលរដ្ឋពិភពលោក" ។

បេតិកភណ្ឌពិភពលោក ជាអំណោយរបស់មនុស្សជាតិដល់ជំនាន់ក្រោយ ។ ទោះជាបេតិកភណ្ឌរូបីក្ដី អរូបីក្ដីនៃពិភពលោកជាកម្មសិទ្ធិរបស់មនុស្សទាំងអស់គ្នាដែលម្នាក់ៗត្រូវតែជួយការពារ និង ថែរក្សា ។

លោក : **យស់ អ៊ាង**

ប្រភព : *Le patrimoine mondial*

"ខ្ញុំមិនចង់អោយផ្ទះខ្ញុំព័ទ្ធព័ន្ធដោយជញ្ជាំងគ្រប់ទិសទី និង បង្អួចបិទជិតរឹងមាំនោះទេ ។ ខ្ញុំចង់អោយវប្បធម៌គ្រប់ប្រទេសទាំងអស់ អាចបក់ចូលឆ្លងកាត់ផ្ទះខ្ញុំដោយសេរីដែលអាចធ្វើទៅបាន ។ ប៉ុន្តែខ្ញុំមិនព្រមអោយវប្បធម៌ណាមួយនាំខ្លួនខ្ញុំទៅបាននោះឡើយ ។

មហាត្មៈគន្ធី

*" Je ne veux pas que ma maison soit entourée de murs de toutes parts et mes fenêtres barricadées. Je veux que les cultures de tous les pays puissent souffler aussi librement que possible à travers ma maison. Mais refuse de me laisser emporter par aucune. "*

*Mahatma Gandhi*



# ចិត្តវិទ្យា-អប់រំ

## តើគ្រូបង្រៀនដោយប្រើវិធីណា?

តាមមតិរបស់ចិត្តវិទូបានប្រកាសអោយដឹងថា នៅក្នុងថ្នាក់រៀននីមួយៗតែងតែមានសិស្សបីប្រភេទ :

- ប្រភេទសិស្សព្យាយាមរៀនឆាប់ចេះ ព្រមទាំងមានចិត្តចង់រៀន ។
- ប្រភេទសិស្សព្យាយាមរៀនសូត្រ ប៉ុន្តែត្រូវការពេលវេលាវែងដើម្បីសាកល្បងគិត និង ដោះស្រាយបញ្ហា។
- ប្រភេទទីបី ជាសិស្សមិនចង់រៀនសូត្រ ព្រមទាំងមានះមិនស្តាប់ រឺមិនធ្វើតាមមតិណែនាំ ។

សិស្សប្រភេទចុងក្រោយនេះ បើគ្រូដាក់កិច្ចការអោយធ្វើនៅផ្ទះច្បាស់ជាគេមិនធ្វើទេ សិស្សប្រភេទនេះ ចិត្តវិទូបានតំរូវអោយគ្រូប្រើវិធីមួយដែលគ្រូដាក់កិច្ចអោយរៀនធ្វើក្នុងថ្នាក់តែម្តង ។ យើងតែងតែនិយាយអំពីគោលការណ៍សិស្សមជ្ឈមណ្ឌល បានន័យថាឆ្លើយតបទៅតាមប្រភេទ រឺតំរូវការរបស់សិស្សជាកត្តាសំខាន់ ។ ដូចនេះ បើយើងអនុវត្តទៅតាមមតិរបស់ចិត្តវិទូខាងលើ បានន័យថាវិធីរៀនរបស់សិស្សក្នុងថ្នាក់នីមួយៗមិនដូចគ្នាទេ ។ សិស្សខ្លះពូកែខាងស្តាប់ សិស្សខ្លះទាល់តែបានអនុវត្តទើបរៀនចេះ សិស្សខ្លះទាល់តែបានសង្កេតទើបរៀនចេះ ។

ដូចនេះ វិធីបង្រៀនរបស់លោកគ្រូ អ្នកគ្រូត្រូវតែផ្សេងៗប្លែកៗ ដើម្បីធ្វើអោយសិស្សគ្រប់គ្នានៅក្នុងថ្នាក់មានការអភិវឌ្ឍរីកចំរើន មានន័យថាបើគ្រូប្រើរបៀបបង្រៀនតែមួយបែបដូចជាវិធីរ៉ាយរ៉ាប់ជាដើមនោះ ចំពោះសិស្សដែលមានវិធីរៀនផ្សេងពីវិធីបង្រៀននេះ ពួកគេពិតជាមិនទទួលបាននូវចំណេះដឹងទេ ព្រោះថាសិស្សខ្លះទាមទារពេលវេលាសំរាប់ធ្វើការអនុវត្ត ។

ជាយូរឆ្នាំណាស់មកហើយ គ្រូបង្រៀនតែងតែប្រើប្រាស់វិធីរ៉ាយរ៉ាប់ដែលចាត់ទុកថា សិស្សមានមូលដ្ឋានក្នុងការគិត ចេះប្រើភាសាដូចគ្នា រឺសុទ្ធតែស្តាប់តាមដំបូន្មានសេចក្តីណែនាំរបស់គ្រូដូចគ្នា នេះជាការភាន់ច្រឡំ ។ គ្រូប្រភេទនេះ ជាគ្រូខ្វះប្រសិទ្ធភាពនៅក្នុងសាលារៀននាសម័យទំនើបបច្ចុប្បន្ន ។ ដូចនេះ លោកគ្រូ អ្នកគ្រូត្រូវតែយកវិធីបង្រៀននានាមកប្រើផងដែរ ដើម្បីកាត់បន្ថយវិធីរ៉ាយរ៉ាប់ ពោលគឺខិតខំយកវិធីបង្រៀនទំនើបមក

ជំនួសដោយគិតគូរអំពីរបៀបរៀនរបស់បុគ្គលម្នាក់ៗ ព្រមទាំងតំរូវការបុគ្គល ដើម្បីរួមចំណែកអភិវឌ្ឍទាំងសិស្សពូកែ ទាំងសិស្សខ្សោយផងដែរ ព្រោះថាសិស្សខ្សោយជាសិស្សដែលកំពុងជួបនូវបញ្ហាធ្ងន់ធ្ងរ ។ សិស្សប្រភេទនេះ បំរុងតែនឹងបោះបង់ចោលសាលារៀន ។

ម្យ៉ាងវិញទៀត តាមលទ្ធផលស្រាវជ្រាវរបស់ចិត្តវិទូជប៉ុននៅឆ្នាំ ២០០២ បានរកឃើញថាគ្រូត្រូវយកចិត្តទុកដាក់ជាប្រចាំដើម្បីអភិវឌ្ឍប៉ិនិនរៀនសូត្ររបស់សិស្ស (Learning skill) ។ ប៉ិនិនរៀនសូត្ររបស់សិស្ស មិនមែនជាអ្វីដែលគេទទួលបានពីកំណើតទេ ។ ប៉ិនិនរៀនសូត្រមានដូចជា ប៉ិនិនសង្កេត ប៉ិនិនចោទជាសំនួរ ប៉ិនិនគិតដោះស្រាយបញ្ហា ប៉ិនិនសរសេរ ប៉ិនិនស្តាប់ ប៉ិនិនបង្កើតសេចក្តីសន្និដ្ឋាន រឺប៉ិនិនបង្កើតសម្មតិកម្ម ។

លោកគ្រូ អ្នកគ្រូយើងតែងតែសន្មតថា សិស្សមានហើយមិនបាច់យកចិត្តទុកដាក់ដើម្បីអភិវឌ្ឍប៉ិនិនរៀនសូត្រទេ នេះជាទស្សនៈភាន់ច្រឡំមួយ ។ តាមរយៈម៉ោងបង្រៀននីមួយៗ យើងត្រូវតែយកចិត្តទុកដាក់ទៅដល់ការបណ្តុះប៉ិនិនរៀនសូត្ររបស់សិស្សដោយផ្តល់ឱកាសអោយសិស្សខិតខំសង្កេត គិត សន្និដ្ឋាន ដើម្បីឆ្លើយនឹងសំនួរ ។

<u>ឧទាហរណ៍</u>: ការបង្រៀនវិទ្យាសាស្ត្រស្តីអំពីត្រីវិស័យ ។ គ្រូមួយចំនួនបាននិយាយពន្យល់អំពីខ្លឹមសារមេរៀនទៅដល់សិស្សតែម្តង រួចហើយហៅមេរៀនអោយសិស្សកត់ត្រា រឺចំលងមេរៀនលើក្តារខៀន រឺបែងចែកសិស្សជាក្រុមដើម្បីអោយសិស្សពិភាក្សាសំនួរទាក់ទងនឹងខ្លឹមសារដែលគ្រូបានពន្យល់រួច ។ នេះជាវិធីបង្រៀនមួយ ដែលពន្យល់ការពិតគ្រង់ៗទៅដល់សិស្សតែម្តង គេពោលម្យ៉ាងទៀតហៅថាវិធីបង្រៀនផ្ទាល់ (Direct Method) រឺគ្រូមជ្ឈមណ្ឌល ។ វិធីបែបនេះ មិនបានរួមចំនែកបណ្តុះប៉ិនិនរៀនសូត្រដល់សិស្សទេ ។ បើចង់អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូត្រូវត្រៀមសំភារៈមួយចំនួនដូចជា ត្រីវិស័យ មេដែក ម្ជុល ចេសសំរាប់ដេរ កែវជ័រ ពណិថ្លា រឺសំបកដបទឹកបរិសុទ្ធ រួចហើយលោកគ្រូ អ្នកគ្រូ ចាប់ផ្តើមចោទជាសំនួរថា :

ចូរប្អូនឆ្លើយនឹងសំនួរដូចខាងក្រោម ÷

១. តើត្រីវិស័យផ្សំដោយផ្នែកណាខ្លះ ?

២. ហេតុអ្វីបានជាទ្រនិចត្រីវិស័យអាចវិលបាន ?

៣. ហេតុអ្វីបានជាវាចង្អុលតែទៅរកទិសខាងជើង ?

សិស្សត្រូវបានចែកជាក្រុម យកត្រីវិស័យទៅសង្កេតរួចឆ្លើយទៅនឹងសំនួរខាងលើតាមរយៈការប្រឹងសង្កេតឃើញ និង ការពិភាក្សារកហេតុផលនៅក្នុងក្រុមរបស់ខ្លួន ។

**<u>ការងារអនុវត្ត:</u>**

ការងារអនុវត្តនេះ សំដៅទៅលើសកម្មភាពច្នៃប្រឌិតដែលអនុវត្តដើម្បីអោយកាន់តែយល់ច្បាស់ខ្លឹមសារមេរៀន មិនមែនសំរាប់អនុវត្តទៅពេលប្រកបរបរចិញ្ចឹមជីវិតដូចគ្រូយើងមួយចំនួនយល់ច្រឡំទេ ។

<u>ឧទាហរណ៍</u>: គ្រូផ្តល់ដបទឹកបរិសុទ្ធដែលកាត់រួច ចេសសំរាប់ដេរ ម្ជុលមួយ ខ្មៅដៃមួយ មេដែកមួយ រួចហើយអោយក្រុមនីមួយៗពិភាក្សាធ្លាកសាងអោយបានត្រីវិស័យមួយ ។

គ្រូមិនប្រាប់អ្វីទាំងអស់ ដោយទុកឱកាសអោយសិស្សខិតខំគិតដោះស្រាយបញ្ហាតាមក្រុមនីមួយៗ នេះជាវិធី

បង្រៀនបែបដោះស្រាយបញ្ហា (Problem solving) ។ សិស្សខិតខំគិតព្រមទាំងធ្វើសកម្មភាពសាកល្បង ដើម្បីបង្កើតអោយបានត្រិវិស័យមួយ ។

**ទិគ្គនគ:** ការធ្វើបែបនេះទើបចាត់ទុកថា ជាគោលវិធីសិស្សមជ្ឈមណ្ឌល ព្រោះសិស្សដើរតាមជំហានអ្នកប្រាជ្ញវិទ្យាសាស្ត្រ ពោលគឺដៃខិតខំធ្វើសកម្មភាព ខួរក្បាលប្រឹងគិតដែលនៅសម័យបច្ចុប្បន្នគេហៅថា "La main à la pâte ដៃប្រលាក់ម្សៅ" រីរៀនតាមរយៈការប្រឹងប្រែងដោះស្រាយបញ្ហាដោយសិស្សនេះឯង ។

វិធីបង្រៀនបែបនេះ ធ្វើអោយរីកចំរើនបំនិនសង្កេត គិត ដោះស្រាយបញ្ហា ព្រមទាំងសិស្សសប្បាយនឹងរៀនទៀតផង ។ ទឹកចិត្តសប្បាយនេះហើយ ដែលជាប្រភពអោយសិស្សមានចិត្តចង់រៀនព្រមទាំងខិតខំរៀនដោយខ្លួនឯងទៀតផង ។

ដូចនេះ គោលវិធីសិស្សមជ្ឈមណ្ឌលតំរូវអោយគ្រូកាត់បន្ថយវិធីបង្រៀនផ្ទាល់ (Direct method) រីវិធីប្រាប់ត្រង់ៗដល់សិស្សដោយយកវិធីបង្រៀនតាមបែបស្រាវជ្រាវដោះស្រាយបញ្ហាមកជំនួសវិញ ។

(នៅមានត)

បណ្ឌិត **អ៊ុំ ភុច**

## សប្បុរិសធម៌ ៧ យ៉ាង :

១. ធម្មញ្ញុតា : ភាវៈជាអ្នកស្គាល់ហេតុនៃផល ។

២. អត្ថញ្ញុតា : ភាវៈជាអ្នកស្គាល់ផលនៃហេតុ ។

៣. អត្តញ្ញុតា : ភាវៈជាអ្នកស្គាល់ឋានៈរបស់ខ្លួន ហើយប្រព្រឹត្តឱ្យសមគួរតាមឋានៈ ។

៤. មត្តញ្ញុតា : ទំនងជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកចិញ្ចឹមជីវិត ។

៥. កាលញ្ញុតា : បែបជាអ្នកស្គាល់កាលវេលាដ៏សមគួរ ។

៦. បរិសញ្ញុតា : របៀបជាអ្នកស្គាល់ប្រជុំជន និង កិរិយាដែលត្រូវប្រព្រឹត្ត ។

៧. បុគ្គលបរោបរញ្ញុតា : សណ្ឋានជាអ្នកស្គាល់អធ្យាស្រ័យនៃបុគ្គល ។

(គតិលោក)

* តើអ្នកដែលបានគិតពីភាវៈផ្ទាល់ខ្លួនអ្នកដែរឬទេ ?

# ដំណើរការនៃញាណវិច្ឆតាខាងបញ្ញា

*(Les processus de la curiosité intellectuelle)*

ការកើតចេញពីឧទ្ទរមាតា គឺជាការឆ្លងចូលដល់ភពថ្មីដែលទារកពុំដែលធ្លាប់បានស្គាល់ទាល់តែសោះ ។ដូចនេះ ពេលកើតឡើងភ្លាម ទារកកើតការឆ្ងល់ ជួនកាលស្រែកយំ ជួនកាលបើកភ្នែកសំលឹងចុះឡើងមិនចេះដាច់ ។ គេមានអច្ឆិតាមួយក្នុងការស្វែងយល់ភាវៈជាមនុស្ស នោះគឺញាណិច្ឆតា[១] ។

## I. ដំណាក់នៃញាណវិច្ឆតា:

នៅក្នុងការស្តែងចេញអោយឃើញពីញាណិច្ឆតា គេអាចបែងចែកវាជាបីដំណាក់ដែលមិនមានភាពចាំបាច់ក្នុងការកើតមានឡើងក្នុងពេលដំណាលគ្នា :

### ដំណាក់ទី១ : ភាពងឿងឆ្ងល់របស់កុមារចំពោះវត្ថុសំរាប់លេងកំសាន្ត

ដំណាក់នេះស្តែងចេញ អោយឃើញនូវដំណើរការបាត់បង់ភាពសំរបសំរួលដែលកំពុងតែកើតមានឡើងការកាត់ផ្តាច់ភ្លាមៗនូវតុល្យភាព និង ការរាំងស្ទះនូវដំណើរការនៃការគិតពីមុន ។ តាមរយៈដំណាក់នេះ វាចាប់ផ្តើមបង្កើតអោយមានការតំរង់ទិសបំរុងប្រយ័ត្នថ្មីមួយ ។ ចំពោះអ្វីៗដែលជាប់ទាក់ទិននឹងស្ថានភាពនោះ គឺអ្នកដែលផ្តោតស្មារតីតាមបែបសំលឹងមើលដោយចំហមាត់ ។

### ដំណាក់ទី២ : ការរំភើបចិត្តចំពោះវត្ថុចំលែក

ក្នុងដំណាក់នេះ គេបកស្រាយពីការសំរបសំរួលបំរុងប្រយ័ត្នតាមបែបងឿងឆ្ងល់ និង ការកន្ត្រាក់អារម្មណ៍ទៅលើការស្វែងយល់ដឹង ។ ចូរយើងយល់ដឹងថា ការរំភើបចិត្តចំពោះវត្ថុចំលែកដ៏ពិត ខណៈដែលកើតមានឡើងបន្ទាប់ពីដំណាក់នៃការងឿងឆ្ងល់របស់កុមារចំពោះវត្ថុសំរាប់លេងកំសាន្ត ឬក៏ភាពអសកម្មដ៏ពិតៗ ចំពោះទឹកចិត្តដែលបៀតបៀនទៅលើការកើតមានភ្លាមៗ ហើយលាយឡំទៅនឹងសកម្មភាពដែលកើតឡើងពីបំណងប្រាថ្នានៃការស្រាវជ្រាវផង[1] ។ ការរំភើបចិត្តចំពោះវត្ថុដ៏ចំលែកនេះ គេអាចនិយាយបានថា ដំណាក់នេះធ្វើអោយយើងភ្ញាក់រំលឹកពីការលង់លក់នៅក្នុងគម្ពីរនិយម ដែលយើងអាចយល់ដឹងបានយ៉ាងងាយស្រួលនូវភាពប្រាកដប្រជានៃការតំរង់ទិសមួយប្រកបដោយសុជីវធម៌ដ៏ត្រឹមត្រូវ ។ ពិភពលោកយើងសព្វថ្ងៃនេះ ជាពិភពដែលមនុស្សលោករស់នៅតាមបែបស្និទ្ធស្នាលជាមួយគ្នា ជាពិភពលោកមួយប្រកបដោយភាពរាប់រកគ្នាយ៉ាងខ្ជាប់ខ្ជួន ហើយជាពិសេសដែលកុមាររស់នៅផង ។ នៅក្នុងពិភពបែបណានោះ ដែលបាតុភូតខុសប្រក្រតីកើតមាននោះធ្វើអោយកុមារមានការងឿងឆ្ងល់ ហើយការរំភើបចិត្តរបស់កុមារចំពោះវត្ថុដ៏ចំលែកនោះ វានៅជិតស្និទ្ធជាមួយយើង ។ អ្វីៗដែលកុមារចង់បាន គឺត្រូវរៀបចំវាអោយឋិតនៅក្នុងភាពមានសណ្តាប់ធ្នាប់ ពោលគឺភាពខុសពី ប្រក្រតីនេះឯងដែលអាចឈប់មានអត្ថិភាពចំពោះកុមារ ។ ក៏ប៉ុន្តែដូចយើងបានបញ្ជាក់រួចមកហើយថា ហេតុការណ៍ ដែលធ្វើអោយកុមារមានការ

(1) *Legrand, Pédagogie de l'étonnement, p.86*

(១) ការចង់ដឹង សេចក្តីប្រាថ្នា

រំភើបចិត្តចំពោះវត្ថុដ៏ចំលែកនោះឯង ដែលនាំអោយកុមារចាប់ផ្តើមសួរមនុស្សចាស់ ។ កុមារមិនមែនស្ថិតនៅតាមបែបអសមត្ថភាពក្នុងការស្វែងយល់ដឹងបានពីអត្ថិភាពនៃវត្ថុដ៏ចំលែក ហើយកុមារក៏មិនមែននៅធ្ងឹងមួយកន្លែងដែរ តែវាជាឱកាសមួយដែលធ្វើអោយកុមារមិនសប្បាយចិត្តនៅក្នុងស្ថានភាពបែបនេះ ។

**<u>ដំណាក់ទី៣</u> : សំនួរតាមបែបចង់ដឹង**

ដំណាក់នេះស្តែងចេញអោយឃើញនូវការយកចិត្តទុកដាក់ចំពោះបញ្ហា ការប្រកាន់ខ្ជាប់នូវសតិសម្បជញ្ញៈទៅលើបញ្ហាបែបណាមួយ និង បំណងប្រាថ្នានៃការចេះសំរបសំរួលខ្លួនជារហូត ។ សំនួរតាមបែបចង់ដឹងអាចចាប់ផ្តើមធ្វើបានចំពោះកុមារទៅតាមរូបភាពជាសំនួរ ពីព្រោះសំនួរបែបនេះ គឺគេប្រើប្រាស់សំរាប់សួរកុមារឱ្យមានសមត្ថភាពចេះឆ្លល់ទៅលើអ្វីៗដោយខ្លួនឯង ។ ដូចដែលលោក Legrand[2] បានពិនិត្យសង្កេតរួចមកហើយ ហើយរកឃើញថា : "ចំពោះកុមារ សំនួរគឺសំដៅធ្វើអោយកុមារទាមទារអ្នកជួយជ្រោមជ្រែង តំរូវការចំពោះការបកស្រាយពន្យល់ គឺជាតំរូវការមួយពីអ្នកដទៃដូចជា ការទ្រទ្រង់ខាងផ្នែកសីលធម៌ និង តំរូវការនៃវត្តមានរបស់អ្នកដទៃ" ។ ដោយចោទជាសំនួរងឿងឆ្ងល់ក្នុងខ្លួនបែបនេះកុមារដែលឋិតនៅឃ្លាតឆ្ងាយពីការយល់ដឹងបានដោយខ្លួនឯង ហើយមិនអាចច្រានចោលបាននូវអ្វីៗដែលគេចង់ឃើញ ចង់ដឹងនោះ មនុស្សចាស់ត្រូវចេះចោទជាសំនួរទៅតាមលំដាប់លំដោយ ហើយត្រូវផ្លាស់ប្តូររូបភាពនៃសំនួរនោះផង ។

គេអាចញែកអោយដាច់ពីគ្នាបាននូវញាណិច្ឆតាទាំងសន្ទុះចិត្ត ដែលជារូបភាពនៃសំនួរមួយប្រកបដោយលក្ខខណ្ឌតាមបែបការរំភើបចិត្តចំពោះវត្ថុចំលែក និង ការងឿងឆ្ងល់ចំពោះវត្ថុសំរាប់លេងកំសាន្ត ហើយនិងញាណិច្ឆតាតាមបែបពុះកញ្ជ្រោលមុនពេលដែលកុមារនោះឋិតនៅក្នុងឥរិយាបថមួយដ៏សាមញ្ញក្នុងការសួរតាមបែបងឿងឆ្ងល់ ។ សំនួរតាមបែបងឿងឆ្ងល់នេះ មុនដំបូងកើតមានឡើងចំពោះការអនុវត្ត បន្ទាប់មកគឺទ្រឹស្តី ។ រូបភាពនៃសំនួរបែបនេះសំរាប់បំបាត់នូវញាណិច្ឆតាទាំងសន្ទុះចិត្តនេះឯង ហើយជាការពិតណាស់សំនួរប្រភេទនេះ មិនអាចកាត់ផ្តាច់បានពីការអប់រំសតិបញ្ញារបស់កុមារបានឡើយ ។

**II. <u>រូបភាពនៃញាណិច្ឆតាដែលកើតឡើងតាមដំណាក់:</u>**

មុនអាយុ ៣ឆ្នាំ អ្នកស្រាវជ្រាវពិនិត្យសង្កេតទៅលើអ្វីៗដែលគេអាចហៅបានថា "អ្នកងឿងឆ្ងល់នៅបឋមវ័យ" ។ រូបភាពនៃការស្តែងចេញជាវាចានេះ គឺមិនមែនប្រើពាក្យថា "ហេតុអ្វី?" ទេ តែមានប្រើពាក្យថា "**ឯណា?**" និង ពាក្យថា "**ស្អីនេះ?**" ។ សំនួរដែលកុមារចោទសួរនោះ គឺពាក់ព័ន្ធទៅនឹងទីកន្លែង ហើយនិងការហៅឈ្មោះ ( វត្ថុ បាតុភូត មនុស្ស សត្វ រុក្ខជាតិ) ។

ចាប់តាំងពីអាយុ ៣ឆ្នាំឡើងទៅ កុមារឈានចូលដល់ "អ្នកងឿងឆ្ងល់នៅវ័យទីពីរ" ។ កុមារដែលឋិតនៅក្នុងវ័យនេះ លែងចង់ស្គាល់ឈ្មោះវត្ថុហើយនិងហេតុផលដែលគេជួបប្រទះហើយ ។ គឺជាវ័យដែលកុមារប្រើពាក្យងឿងឆ្ងល់ថា "**ហេតុអ្វី?**" ។ ដូចដែលលោក Osterrieth[3] បានធ្វើការកត់សំគាល់ឃើញថា "ការប្រើសំនួរ ហេតុអ្វីនេះ គឺពិតជាមុខងារនៃបញ្ញាញាណទៅលើពតិមាន ហើយវាជាការពិតណាស់ នោះគឺជាមុខងារផ្លូវចិត្តដែលជាប់ជំពាក់

*(2) Legrand O.C p.65, (3) Introduction de la psychologie de l'enfant. p.108*

ទៅតាមកំណើនសរីរាង្គឈានទៅរកវ័យចំណាស់ ដោយទាមទារអោយមានការពង្រឹងបាននូវបំរុងប្រយ័ត្ន ការចេះធានាបានលើខ្លួនឯង ការចេះបង្ក្រាបបាននូវភាពតប់ប្រមល់ដែលកើតមានក្នុងខ្លួន នៅក្នុងលោកដែលខ្លួនរស់នៅ ហើយដែលអ្នកផងអាចយល់ដឹងបានថា : កុមារអាចបណ្តុះបាននូវអត្តចរិតដោយឥតគ្រោងទុក ចេះប្រកាន់បាននូវចរិយាធម៌ និង ចេះប្រើប្រាស់វត្ថុនានាដែលមនុស្សចាស់ណែនាំអោយចេះប្រើ" ។ លោក Stern[4] បានកត់សំគាល់ឃើញថា : "នេះជាទិដ្ឋភាពទី ១ នៃការជាប់ជំពាក់ក្នុងចិត្តនូវពាក្យថា : "ហេតុអ្វី?" ដែលអាចបញ្ជាក់បាននូវពាក្យថា "ស្រងាកចិត្ត" នៅពេលដែលវត្ថុដែលខ្លួនគេចង់ឃើញនោះ ទៅជារកមិនឃើញ ។ ខុសគ្នាស្រឡះពីលោក Piaget លោក Legrand បានពិនិត្យឃើញថា "នៅក្នុងសំនួរដែលតំរូវអោយសិស្សប្រាប់ពីទីកន្លែងនៃវត្ថុ មនុស្ស សត្វ សិស្សមិនអាចប្រាប់បានតាមសំណូមពរឡើយ" ហើយសអោយឃើញថា នៅក្នុងវ័យកុមារភាពតែងតែស្តែងអោយឃើញនូវភាពកង្វល់ចិត្តប្រកបដោយបុព្វហេតុ និង គោលការណ៍ជាបឋមដែលឈានទៅរកការលេចធ្លោឡើងនូវភាពគ្រប់ការនោះឯង ។

នៅក្នុងអំឡុងវ័យកុមារភាពទី ២ (គិតពីអាយុ ៣ ទៅ ៧ឆ្នាំ) ញាណិច្ឆតាតំរង់មុខសញ្ញាទៅរកសំនួរ "យ៉ាងដូចម្តេច?", "**ដោយសារអ្វី?**"នេះម្យ៉ាង ហើយម្យ៉ាងទៀតគឺតំរង់មុខសញ្ញាទៅរករូបភាព "**ស្អីខ្លះ?**" ឧទាហរណ៍ : មេអំបៅមានសរសៃឈាម ចុះវាទិចមនុស្សឬទេ ? ឬក៏សំនួរមានរូបភាព "ម៉េចក៏អញ្ចឹងទៅវិញហ្នំ" (នេះជាញាណិច្ឆតាក្នុងអតីតកាល ហើយពាក់ព័ន្ធទៅនឹងចំណង់ចំណូលចិត្តរបស់កុមារក្នុងប្រវត្តិសាស្ត្រ) ។ ការវិវត្តបែបនេះ អាចក្លាយទៅជារឿងពិតនៅពេលដែលកុមារឈានទៅរកវ័យកុមារភាពទី ៣ ។

នៅវ័យ ៨ឆ្នាំដែលគេហៅថា "វ័យមហិច្ឆតា ឬវ័យជម្លើយ" បានបង្ហាញអោយឃើញថា "មានការរីកដុះដាលនូវសរីរាង្គកាយដ៏ចំលែក និង ពិភពសតិអារម្មណ៍" ។ លោក Osterrieth បានកត់សំគាល់ឃើញថា : "កុមារមិនមែនរស់នៅកន្លែងនេះតែរហូតទេ ប៉ុន្តែកុមារថែមទាំងចាប់អារម្មណ៍ទៅលើមនុស្សក្នុងសម័យបុរេប្រវត្តិ ឬមនុស្សរស់នៅលើកោះអាកទិច ពិភពរុក្ខជាតិ និង សត្វ ធាតុភូតនៃការធំធាត់ និង បន្តពូជរបស់មនុស្ស សត្វ និង រុក្ខជាតិ ។ ទន្ទឹមនឹងនេះ បញ្ហាមរណៈក៏ជាបញ្ហាដែលចោទឡើងនៅក្នុងញាណិច្ឆតារបស់កុមារដែរ ។ ដោយលើកឡើងពីល្បែងកំសាន្តទៅតាមភេទ និង ការស្រាវជ្រាវផ្នែកកាយវិភាគក្នុងវ័យនេះ លោក Osterrieth បានសរសេរថា : "វាមើលទៅហាក់ដូចជាសកម្មភាពទាំងនេះមិនសូវមានលក្ខណៈជាប់ពាក់ព័ន្ធទៅនឹងកាមរោគ និង សេចក្តីស្នេហាតាំងពីដើមវ័យមកម្ល៉េះ ហើយសំលេងនិយាយរបស់គេកាន់តែមានលក្ខណៈជាបញ្ញវន្ត"[5] ។

នៅវ័យ ៩ឆ្នាំ គេសង្កេតឃើញថា កុមារមានការស្រេកឃ្លានខាងចំណេះដឹងដែលតំរង់មុខសញ្ញាទៅរកការប្រមូលផ្តុំបាននូវទិន្នន័យពីគ្រប់លំដាប់ថ្នាក់ទាំងអស់ ។ ប៉ុន្តែគេគួរកត់សំគាល់បានថា តាមគំនិតរបស់លោក Gesell គេឃើញមាននិន្នាការមួយ ដែលគេកត់សំគាល់បានយ៉ាងច្បាស់ក្នុងការធ្វើសមាហរណកម្មនូវទិន្នន័យទាំងនេះ ទៅក្នុងសំណុំនៃចំណេះដឹងដែលមានលក្ខណៈកាន់តែទូលំទូលាយក្នុងការរៀបចំចំណេះដឹងនោះអោយផ្សារភ្ជាប់គ្នា ។ លោក Osterrieth បានផ្តល់ឧទាហរណ៍នៃទិន្នន័យពតិមានទាំងនោះ ដូចតទៅ : "ចំណង់ចំណូលចិត្តរបស់កុមារ

*(4) Legrand, O.C p.197, (5) Legrand, O.C p.208*

ចំពោះឋានន្តរសក្តិយោធា ឬមុខងារសាធារណៈ និង បុណ្យសក្តិទៅតាមលំដាប់ថ្នាក់ដែលកុមារជាប់ជំពាក់ចិត្ត ។ ជួនកាលចំណេះដឹងរបស់កុមារធ្វើអោយកុមារមានការរំភើបក្នុងចិត្តយ៉ាងខ្លាំងចំពោះប្រភេទរថយន្ត ឬប្រភេទយន្តហោះ ចំណង់ចិត្តរបស់គេក្នុងការចងក្រងពត៌មាននៃចំណេះដឹង តំរូវការនៅក្នុងចំណងមិត្តភាពរវាងសាច់ញាតិនៃគ្រួសារមួយ និង បញ្ហាដែលចោទឡើង ។ នៅទីបំផុត គឺអ្វីៗដែលជាប់ទាក់ទិនទៅនឹងអាជ្ញាធរចំពោះបុគ្គលប្រភេទណាមួយនោះ ឬក៏កំលាំងដែលកើតឡើងជាបន្តបន្ទាប់នៃគ្រឿងផ្ទុះទៅតាមទិសដៅផ្សេងៗគ្នា"[(6)] ។

មុខសញ្ញាមួយដែលផ្សារភ្ជាប់ទៅនឹងញាណិច្ឆតារបស់កុមារដែលមានវ័យពី ៦ ទៅ ១២ឆ្នាំ ដែលគត់សំគាល់ឃើញដោយលោក Mucchielli នៅក្នុងហេតុការណ៍ដែលថា កុមារតាមឃ្លាំមើលឪពុកម្តាយរបស់គេ ចេះស្តាប់ និងវិនិច្ឆ័យពីអ្វីៗដែលឪពុកម្តាយគេបាននិយាយ បានលើកឡើងពីសញ្ចេតនារបស់ឪពុកម្តាយគេចំពោះរូបគេ ។ លោក Mucchielli បានគិតឃើញថា គេបានធ្វើអោយលេចធ្លោឡើងនៅត្រង់ចំណុចនេះនូវការបំផុសចេញបាននូវគំនិតមួយដ៏ស៊ីជំរៅនៃញាណិច្ឆតា ពីព្រោះ "ដើម្បីធ្វើអោយខ្លួនគេ និង ពិភពដែលគេប្រាថ្នាធ្វើអោយមានអត្ថិភាព នោះគឺក្នុងវ័យនេះហើយ ហើយនិងនៅក្នុងទស្សវត្សក្នុងអនាគតកាលនេះឯងដែលធ្វើឱ្យគេយល់ដឹងបានពីអាថ៌កំបាំងនៃប្រភពសច្ចធម៌" ។

### III. **<u>ការអប់រំញាណិច្ឆតា</u>**

ជាការពិតណាស់ ញាណិច្ឆតាអាចកាត់បន្ថយបាននូវវិបុលកម្មនៃបទពិសោធន៍ ក៏ប៉ុន្តែញាណិច្ឆតានេះធ្វើអោយមានកំណើននៃឥទ្ធិពលផ្នែកត្រិះរិះពិចារណាទៅតាមស្មារតីមួយដែលអាចប្រមូលផ្តុំបាននូវបទពិសោធន៍ ដើម្បីឱ្យញាណិច្ឆតាទៅជាមានលក្ខណៈកាន់តែរលូន ឬក៏អាចចុះខ្សោយវិញទៅតាមលំដាប់ ។

ជួនកាល ញាណិច្ឆតាជាច្រកមួយសំរាប់ឈានទៅរកតថភាព ហើយចោទជាបញ្ហាឡើងទៅលើតថភាពនេះដោយបង្កើតបាននូវមធ្យោបាយមួយដ៏មានតំលៃសំរាប់ការសិក្សា និង ការអប់រំស្មារតីនេះឯង ។ ក៏ប៉ុន្តែ បំរើបំរាស់មធ្យោបាយនេះ ទាមទារអោយមានបំរុងប្រយ័ត្នដ៏ប្រាកដប្រជាផងដែរ ។

ដើមឡើយ គេមិនគប្បីគក់ក្រហល់ក្នុងការបង្ខិតបង្ខំធ្វើអោយមានញាណិច្ឆតាដែលជាឯកទេសមួយដ៏ម៉ឺងម៉ាត់ពីព្រោះសំនួររបស់កុមារច្បាស់ជាមិនអាចផុសចេញនូវចំលើយ ឬរបកគំហើញបែបណាមួយភ្លាមៗបានទេ ។ ជាប្រតិមតិ គេអាចនិយាយបានផងដែរពីការ "និយាយស្តាប់មិនបាន" ប្រកបដោយផ្លែផ្កាចំពោះលក្ខខណ្ឌដែលគេមិនអាចពន្យាពេលវេលាដោយជ្រុលហួស ហើយជាពិសេសសាមីខ្លួនមិនបានគិតពីការសប្បាយទេចំពោះរបកគំហើញនៃស្ថានភាពមានបញ្ហានោះផង ។ វាជាការពិតណាស់ថា សំនួរ "ហេតុអ្វី?" របស់កុមារភាពទី២ ជួនកាលមានគោលបំណងគ្រាន់តែ "បង្ហាញការពិត" ហើយឈានដល់ការបង្ហាញអោយឃើញនូវភាពថ្នាក់ថ្នមពីមនុស្សចាស់ប៉ុណ្ណោះឯង ។

បន្ទាប់មក គេគប្បីចៀសវាងមិនបង្កអោយមានភាពខិនពិការដ៏ពិតប្រាកដនៃញាណិច្ឆតាដោយផ្តល់ដល់កុមារភាពនូវសញ្ចេតនាដែលចោទជាបញ្ហា គឺជាសញ្ញានៃភាពទន់ខ្សោយ កង្វះកំលាំង និងមធ្យោបាយចំពោះអ្នកឯណា

*(6) Legrand, O.C p.206*

ហើយដែលចង់ចោទជាសំនួរ ហើយផ្ទុយទៅវិញការកត់សំគាល់អោយឃើញនូវថាមពល និងមធ្យោបាយចំពោះអ្នកឯណាដែលត្រូវគេសួរអោយផ្តល់នូវចំលើយនោះ ។ ទន្ទឹមនឹងនេះផងដែរ ដូចដែលហេតុការណ៍របស់លោក Legrand ដែលបានពិនិត្យសង្កេតលើបញ្ហានេះ ។ ពពួកគរុកោសល្យវិទូ មិនអាចធ្វើគរថ្លង់បានទេចំពោះវិធីសាស្ត្របង្រៀននៅក្នុងថ្នាក់ ដែលគ្រូអាចបង្កើតអោយមានផងដែរនូវសំនួរពីសំណាក់សិស្សដែលវាជាបញ្ហាធ្វើអោយចង្អៀតចិត្តដែលសំរាប់បង្កើតអោយមានឧបសគ្គចំពោះអ្នកឯណាដែលត្រូវកុមារចោទសួរ ហើយចង់បាននូវចំលើយនោះ ។ "ក្នុងន័យនេះ សំនួរគ្រាន់តែជាឧបកថានៃសង្គ្រាមផ្លូវបញ្ញាញាណដ៏តូចមួយប៉ុណ្ណោះ"[7] ។

នៅទីបំផុត គេត្រូវចៀសវាងកុំអោយញាណិច្ឆតាឋិតនៅក្នុងរយៈពេលដ៏ឆាប់ពេកនៅក្នុងវិស័យទាំងឡាយដែលមានលក្ខណៈប្រាកដប្រជា ។ ជាពិសេស គេមិនត្រូវធ្វើអោយបាត់បង់នូវចក្ខុវិស័យដែលថា "អត្ថន័យនៃសត្យានុម័តមិនមានលទ្ធភាពបង្កើតអោយមានញាណិច្ឆតាតែម្នាក់ឯងបានទេ ចំពោះមនុស្សនៅក្នុងសម័យទំនើបភាពចល័តនៃស្មារតីរបស់មនុស្សមានលក្ខណៈចាំបាច់ណាស់ចំពោះការសំរបសំរួលខ្លួនទៅថ្ងៃអនាគត" ។ ពេលនោះគេត្រូវចេះដឹកនាំញាណិច្ឆតា ចេះតំរង់ទិសវាឆ្ពោះទៅរកវិស័យទាំងឡាយដែលញាណិច្ឆតានោះអាចផ្តល់នូវអត្ថ-ប្រយោជន៍ ចេះប្រើប្រាស់ញាណិច្ឆតាទៅតាមវិធីបែបណាមួយសំដៅផ្តល់នូវមូលដ្ឋានចំពោះស្មារតីដូចជា : មុនដំបូងការចេះប្រើប្រាស់វា បន្ទាប់មកការបង្ហាញនូវធាតុពិត និង គោលការណ៍ដែលមានតំលៃទៅតាមវិធីសាស្ត្រនៃការបង្រៀន ។

បណ្ឌិតសាស្ត្រាចារ្យ : **ចាន់ រដ្ឋសុផា**

( ប្រភព : *J.LEIF – J.DELAY: Psychologie et éducation: T.I: L'enfant.* )

**អង្គរបស់អ្នករៀន (សិក្សាចតុរង្គ)**

**សុ . ចិ . បុ . លិ**

សុ : សុត : ស្តាប់

ចិ : ចិន្ត : គិត

បុ : បុច្ឆ : សួរ ?

លិ : លិខ : សរសេរ កត់ វិចំលង

*(7) Legrand & J. Fourastié, L'Avenir de l'Education, p. 84 février 1984*




## ថ្មបំបែក

តើគេបង្កើតឧបករណ៍យ៉ាងដូចម្តេចនៅយុគថ្មបំបែក ?

យុគថ្មបំបែក( La Paléolithique ) គឺជាប្រវត្តិកាលយូរជាងគេនៃវិវត្តន៍បច្ចេកទេសរបស់មនុស្ស ព្រោះវាមានកំនើតតាំងពី២លានឆ្នាំ ហើយត្រូវបានបញ្ចប់រវាង១លានឆ្នាំមុនគ.ស នៅពេលដែលចាប់កំនើតប្រវត្តិកាលនៃថ្មសំលៀង( La Néolithique ) ។

មនុស្សចេះប្រើប្រាស់ដៃ( Homo habilis ) បានបង្កើតឧបករណ៍យ៉ាងគគ្រើមដំបូងបង្អស់ដោយយកដុំគ្រួសធំៗដដុះគ្នាខាងផ្នែកសំប៉ែត ។

បន្ទាប់មក មនុស្សចេះឈរជើងពីរ( Homo erectus ) ចាប់ផ្តើមកែឧបករណ៍គ្រើមខាងលើដោយអន្លើខ្លះៗដើម្បីធ្វើអោយមានមុខឆ្មារស្រួច និង មានជ្រុង ។ លទ្ធផលនៃការវិវត្តដំណាក់ទី១ គឺការបង្កើតថ្មសំប៉ែតមុខពីរ ។

ចុងបញ្ចប់ មនុស្សបានបង្កើតបច្ចេកទេសច្រៀកថ្មស៊ីឡិច( silex ) ជាសន្លឹកឆ្មារទៅៗ ហើយមានមុខមុតដែលអោយឈ្មោះថាស្លឹកយិតថៅ( Laurier ) ប្លែកៗជាច្រើន ។

ព្រមជាមួយនេះដែរ មនុស្សក៏បានបង្កើតអាវុធប្លែកៗជាច្រើនសំរាប់តាំងនៅជញ្ជាំង( ប្រដាប់កោស ខ្ទាស ខ្សែរ ប្រដាប់ចោះ ពន្លាក ) និង សំភារៈប្រើប្រាស់ច្រើនទៀតក្រៅពីថ្ម ( ឆ្អឹង ភ្លុក ស្នែង ) ។

រួមជាមួយនឹងវិសាលភាពនៃការបង្កើតប្រដាប់ប្រដានោះ មនុស្សបានកែច្នៃបង្កើតអាវុធ ថ្មៃស្បែក ដេរ កែលំនៅស្ថាន និង របៀបស្លៀកពាក់ ។

## បច្ចេកទេសច្រៀកថ្ម

តើគេអាចដឹងថាមនុស្សបុរេប្រវត្តិបានសំរួចព្រួញ រឺលំពែងយ៉ាងដូចម្តេច ?

ប្រមាណជាង៣០ឆ្នាំមកហើយ អ្នកស្រាវជ្រាវបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើការបង្កើតឡើងវិញ

អំពីរបៀបបែបបទក្នុងការកសាងអាវុធអំពីថ្មស៊ីឡិច ។

បូរាណវិទូជាច្រើនបានសាកល្បងធ្វើផ្លែដាវ រឺកាំបិតអំពីថ្មស៊ីឡិចអោយដូចជាផ្លែដាវ រឺកាំបិតដែលគេបានរកឃើញនៅក្នុងកំណាយពីបុរេប្រវត្តិ ។ គេបានសាករកមធ្យោបាយផ្សេង និង ជ្រើសរើសរកវិធីជាក់ស្តែង ។ ការវិភាគទំរង់ថ្មស៊ីឡិច និង កំទេចចំនាំងដែលនៅសល់មិនបានយកទៅប្រើប្រាស់ បានបង្កលក្ខណៈអោយយើងរកឃើញនូវទំរង់ប្រតិបត្តិការជាច្រើន ។ ជាដំបូងអ្នកប្រមាញ់យកប្លុកដុំថ្មយ៉ាងរឹង បំបែកជាគ្រួសស៊ីឡិចមានទ្រង់ទ្រាយដូចជាគ្រាប់ចំបក់ ហើយកំនត់យកមុខមួយសំរាប់ច្រៀកដើម្បីអោយចេញជាផ្លែកាំបិត រឺផ្លែដាវ ។ ចំរៀកនីមួយៗត្រូវបានយកទៅវាយនឹងអន្លូងយ៉ាងរឹង ដើម្បីបង្កើតអោយបានទៅជាមុខពីរ និង មុខស្រួច ។ បន្ទាប់មកទៀត អ្នកប្រមាញ់យកឆ្អឹងសត្វរ៉ែន [១] មកដដុសគែមផ្លែដាវ ហើយការងារនេះប្រព្រឹត្តទៅរហូតដល់បានមុខស្មើសាច់គ្នា ។ ផ្នែកលើផ្លែត្រង់ និង ឆ្នារនោះ គេកសាងបានជាទ្រង់ទ្រាយត្រឹមត្រូវមួយមានផ្ទៃលាតជាផ្លែស្ទមានង្កៀង រឺផ្លែលំពែង ហើយគេលាក់ដើម្បីបញ្ចុះដង ។ ភាពសំបូរបែបនៃការផលិតផ្លែដាវ និង មុខស្រួចនៃថ្មស៊ីឡិចបានបង្ហាញថា ការប្រើប្រាស់វាត្រូវបានផ្សព្វផ្សាយជាសកល ហើយនរណាក៏អាចមានលទ្ធភាពផ្ទាល់ក្នុងការផលិតដែរ ។



ប្រែសំរួល : **កែវ យ៉ារ**

( ប្រភព : *Les civilisations et les hommes*)

---

( ១ ) សត្វចតុប្បាទ ពួកប្រើសរស់នៅក្នុងវាលទឹកកក ប្រើជាសត្វពាហនៈ

# ម៉ាស៊ីនគិតលេខអេឡិចត្រូនិចជាអ្វី?

ម៉ាស៊ីនគិតលេខអេឡិចត្រូនិចដែលខ្មែរយើងនិយមហៅជាទូទៅថា កាស៊ីយ៉ូៗ(*CASIO*)នោះ មានប្រវត្តិវែងឆ្ងាយក្នុងលំនាំនៃការវិវត្តរីកចំរើន ប៉ុន្តែចាប់ផ្តើមពីអ្វីដែលងាយស្រួលយល់ជាទីបំផុត ។

"ម៉ាស៊ីនគិតលេខ" ដំបូងបង្អស់របស់មនុស្សយើង គឺម្រាមដៃ ។ តើអ្នកនៅមានធ្លាប់ប្រើការរាប់ម្រាមដៃដែរឬទេ ? ប្រាកដណាស់ គោលការណ៍យន្តកម្មនៃការរាប់ម្រាមដៃនេះ គ្មានខុសអ្វីបន្តិចណាសោះពីរបៀបគិតគូររបស់ម៉ាស៊ីនគិតលេខអេឡិចត្រូនិចដ៏ទំនើបនោះ ។ ម៉ាស៊ីនគិតលេខវា "បត់" និង "លា" ម្រាមដៃដើម្បីគិតគូរដូចអ្នកដែរ ក្នុងការគណនាអោយបានចេញជាលទ្ធផល ។ ខុសគ្នាតែបន្តិចត្រង់ដែលថា "ម្រាមដៃ"របស់ម៉ាស៊ីនគិតលេខនោះ គឺជាសន្ទុះអេឡិចត្រូនិចរុញចូល ឬច្រានចេញនៅក្នុងឃ្លាំងស្តុកនៃការចងចាំរបស់វា ។ ចលនារបស់វាបែបនេះដូចគ្នាបេះបិទទៅនឹងការបត់ និង ការលាម្រាមដៃជាបន្តបន្ទាប់ជាប់ៗគ្នារបស់អ្នកដែរ ។

ម៉ាស៊ីនគិតលេខពុំមានអ្វីជាមូលដ្ឋានថ្មីនោះទេ ។ ភាពប្លែកគ្នា គឺស្ថិតនៅត្រង់ចំនួន "ម្រាមដៃ"របស់វាច្រើនអនេក មានន័យថាទំហំនៃការចងចាំខ្ពស់ និង ត្រង់ការ "បត់" ឬ "លា" ម្រាមដៃរហ័សបំផុតនោះ គឺល្បឿននៃការគណនា ។

តែប៉ុណ្ណឹងទេឬ ?-មែន ប៉ុណ្ណឹងឯង ! ។

ប៉ុន្តែម៉ាស៊ីនគិតលេខអេឡិចត្រូនិចនៅតែវិវត្តទៅមុខជានិច្ច ក្នុងការដោះស្រាយបញ្ហាការគិតលេខរបស់មនុស្ស និង ជូនកាលហួសពីវិស័យនៃតំរូវការរបស់មនុស្សទៅទៀត ។

ប្រវត្តិរបស់ម៉ាស៊ីនគិតលេខអេឡិចត្រូនិចក៏ដូចជាប្រវត្តិរបស់អ្វីផ្សេងៗទៀតដែរ តែងតែមានជួបវិបត្តិការប្រែប្រួល និង ការភ័ន្តច្រលំ ។ នៅទីនេះ យើងមិននិយាយអំពីវិបត្តិ និង ការភ័ន្តច្រលំទេ យើងលើកឡើងតែពីការប្រែប្រួលរីកចំរើនជាដំណាក់ៗប៉ុណ្ណោះ ។

ប្រជាជនខ្មែរយើង ក្រៅពីរាប់ម្រាមដៃ ហើយបើម្រាមដៃមិនគ្រប់ទេ គេប្រើខ្ទាច់ ។ ឯរបៀបគិតគូរលេខគេមានប្រើក្បាច់[១] ដែរ ។ មកដល់សម័យបច្ចេកទេស វិទ្យាសាស្ត្ររីកចំរើននៅតាមអង្គភាពគណនេយ្យមួយចំនួនគេមានប្រើម៉ាស៊ីនគិតលេខមេកានិចសុទ្ធសាធ គឺវិវៃដោយដៃ តែអាចធ្វើលេខបូក ដក គុណ ចែកបានរហ័សអោយតែចេះវិវៃតាមរបៀបប្រើប្រាស់របស់វា( គេច្រើនហៅតាមឈ្មោះប្លាកសញ្ញាថា *FACIT* ) ។ ក្រោយមកទៀត ទើបឃើញមានម៉ាស៊ីនគិតលេខអេឡិចទ្រិច( អេឡិចត្រូមេកានិច និង អេឡិចត្រូម៉ាញេទិច)ជាបន្តបន្ទាប់មានតំលៃខ្ពស់ ហើយមានប្រើតែនៅតាមក្រុមហ៊ុនធំៗ និង អង្គភាពគណនេយ្យសំខាន់ៗ( មានច្រើនប្រភេទ ច្រើនម៉ាក សញ្ញា *OLIVETTI, ...*) ។

(១)ក្បាច់ : ប្រដាប់សំរាប់គែនលេខ មានស្នូក រាងបួនជ្រុងទ្រវែង មានគ្រាប់ខ័ណ្ឌជាពីរសង្កាត់ ។ សង្កាត់ខាងលើ១ខ្ទង់មាន២គ្រាប់ ក្នុង១គ្រាប់ទុកជា ៥ ។ សង្កាត់ខាង ក្រោម១ខ្ទង់៥គ្រាប់ជាគ្រាប់រាយ ។ ខ្លះហៅក្បាច់ចិន ។

តែចំពោះការវិវត្តពិតប្រាកដនៃម៉ាស៊ីនគិតលេខនោះ មានជាតំណាក់ៗគួរអោយកត់សំគាល់ ។ តំណាក់ដំបូងគឺការបង្កើតម៉ាស៊ីនគិតលេខទីមួយធ្វើឡើងនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៤៤ ដែលមានឈ្មោះថា *Mark-1* ហើយពុំទាន់ជាអេឡិចត្រូនិចនៅឡើយទេ ។ វាមានសមាសធាតុសំខាន់នៃកំលាំងបន្តអេឡិចត្រូម៉ាញេទិច គឺដំណើរការបែបកំលាំងអេឡិចត្រូមេកានិចម្យ៉ាង ពុំមែនជាអេឡិចត្រូនិចនៅឡើយទេ ។ ម៉ាស៊ីនគិតលេខអេឡិចត្រូនិចទីមួយនោះគឺ *ENIAC* បង្កើតក្នុងឆ្នាំ ១៩៤៦នៅសហរដ្ឋអាមេរិកដែលត្រូវប្រើអំពូលអេឡិចត្រូនិច ។ ការវិវត្តមួយតំណាក់ៗ បានបង្កើតអោយមានជំនាន់នៃម៉ាស៊ីនគិតលេខមួយដែលកាន់តែរហ័ស និង មានទំហំនៃការចងចាំកាន់តែរីកធំ( ចំនួន"ម្រាមដៃ") ។ យើងពិនិត្យមើលជំនាន់ នីមួយៗដូចខាងក្រោម :

ជំនាន់ទី 0 គឺម៉ាស៊ីនប្រើកំលាំងបន្ត( *à relais*) ប្រភេទ *Mark-1* ។

ជំនាន់ទី ១ គឺម៉ាស៊ីនប្រើអំពូលប្រភេទ *ENIAC* ( នៅរុស្សីគឺប្រភេទ : *Strela, BESM-2, Oural-2,* ។ល ។)

ជំនាន់ទី ២ គឺម៉ាស៊ីនប្រើត្រង់ស៊ីស្ទ័រដែលកាន់តែតូចណែន និង រហ័ស ។ វាមិនខុសអីពីវិទ្យុត្រង់ស៊ីស្ទ័រដែលកាន់តែតូចទៅៗជាងវិទ្យុប្រើអំពូលនោះទេ ។

ជំនាន់ទី ២ បានទុកកន្លែងអោយជំនាន់ទី ៣ រួចមកជំនួសដោយជំនាន់ទី ៤ ជាបន្តបន្ទាប់ ។ ម៉ាស៊ីនជំនាន់ទី៣ ប្រើប្រាស់ត្រង់ស៊ីស្ទ័រដែរ តែមានវង់ចរន្តបូរណកម្ម (*circuits intégrés*) ។ ម៉ាស៊ីនជំនាន់ទី៣នេះ មានប្រភេទ *BESM-6* ដែលអាចធ្វើលេខបានមួយលានដង ( លេខបូកជាដើម...) ក្នុងមួយវិនាទី ។

ម៉ាស៊ីនជំនាន់ទី ៤ ធ្វើលេខក្នុងល្បឿនរាប់សិបលាន ឬអាចដល់រាប់រយលានដងក្នុងមួយវិនាទី ។ នៅលើវិថីរីកចំរើនដ៏ល្អបែបនេះ គេពុំបញ្ឈប់ការអភិវឌ្ឍថ្មីៗនៅត្រឹមប៉ុណ្ណោះទេ ។ គេនៅតែកែលំអបន្ថែមលទ្ធផលអោយកាន់តែខ្លាំងឡើងជានិច្ច ។

តើបានប្រយោជន៍អីដែលខំរកបានល្បឿននៃការគិតយ៉ាងខ្លាំងបែបនេះ ? តើគេមិនខ្លាចធ្លាក់ចូលទៅក្នុងស្ថានភាពរបស់លោកអាណាតូលហ្វ្រង់[(១)] (*Anatole France*) ទេឬអី ? ស្ថានភាពនោះ គឺថ្ងៃមួយគេបាននាំនារីម្នាក់ដែលជាអ្នកជំនាញខាងជវអង្គុលីលេខ( *sténodactylo*) មកជួបនឹងលោក ។ នាងនោះបានបញ្ជាក់ប្រាប់លោកថា នាងអាចវាយជវអង្គុលីលេខ[(២)] បាន៥00ពាក្យក្នុងមួយនាទី ។ អ្នកនិពន្ធអាណាតូលរំពឹងគិតដោយព្រួយបារម្ភថា : "តើអោយអញទៅរកពាក្យ ពីណាបានច្រើន និង រហ័សអ្វីដល់ម្លេះនោះ ! " ។



**"ម៉ាស៊ីនគិតលេខ" ដំបូងបង្អស់របស់មនុស្ស**



**ក្បាច់**



ម៉ាស៊ីនគិតលេខមេកានិច




កាស៊ីយ៉ូ

លោក : **យស់ អ៊ាង**

( ប្រភព : *La cybernétique telle qu' elle est*)

* * * * * *

គ្រូដែលចេះតែបង្គាប់សិស្សអោយប្រូវប្រយ័ត្នស្មារតីចំពោះមេរៀនដែលខ្លួនបង្រៀន មិនមានគុណសម្បត្តិល្អប្រសើរស្មើនឹងគ្រូដែលចេះពន្យល់ ចេះបង្ហាញផលប្រយោជន៍មេរៀន ចេះធ្វើអោយសិស្សយកចិត្តទុកដាក់ប្រយ័ត្ន ដោយខ្លួនគេនោះទេ ។

**វីលៀម ចេម្ស**

(១) អាណាតូលហ្វ្រង់ ជាអ្នកនិពន្ធបារាំងដ៏ល្បីនៅស.វ.ទី១៩ឈ្មោះដើម *Anatole François Thibault* ។

(២) ការវាយអង្គុលីលេខជាអក្សរកាត់តាមក្បួនខ្នាតអោយទាន់សំដីនិយាយ ។



# ការអប់រំ & គរុកោសល្យ

## លំហាត់បុរេសិក្សា(ត)

.............................................................

### ៣. កុមាររៀនកំនត់ចំនួន

ចូរគូស+លើក្រុមគំនូរច្រើនក្នុងចតុកោណកែងនីមួយៗ




ចូរគូស-លើក្រុមគំនូរតិចក្នុងចតុកោណកែងនីមួយៗ




ចូរគូស+លើក្រុមគំនូរច្រើនក្នុងចតុកោណកែងនីមួយៗ



ចូរគូស-លើក្រុមគំនូរតិចក្នុងចតុកោណកែងនីមួយៗ



ពិនិត្យគំនូរតាមខ្ទង់នីមួយៗ ហើយគូសសញ្ញាស្មើ( = )នៅក្នុងការេដែល មានគំនូរស្មើគ្នាខាងលើ





គូសសញ្ញាស្មើ ( = ) នៅលើផ្ទាំងទាំងឡាយដែលមានស្រទាប់ស្មើនឹងផ្កាខាងលើ



គូស = នៅលើផ្ទាំងទាំងឡាយដែលមានស្លាបព្រាបាយអដូចខាងលើ





| | | |
|---|---|---|
| ចូរភ្ជាប់ខ្សែ១ទៅនឹងរូ | គូសព្រួញលើរូបខាងក្រោមឱ្យដូចរូបខាងលើ | គូសចំនួនបាវនៅលើរទេះទទេឱ្យស្មើនឹងរទេះខាងលើ |



| | | |
|---|---|---|
| គូរចំនួនស្លឹកឈើលើមែកខាងក្រោមឱ្យស្មើនឹងស្លឹកមែកទី១ | គូរជើងសេះលើរូបខាងក្រោមឱ្យស្មើជើងសេះទី១ | គូរក្នុងការេនីមួយៗនូវផ្លែត្រប់ឱ្យស្មើនឹងចំនួនផ្លែត្រប់ក្នុងការេទី១ |



( ប្រភព : *Pédagogie vivaute: l'enfant apprenol à reconnaitre les nombres*) ប្រែសំរួលដោយ : **កែវ យ៉ារ**

# ភាសា

## ឈ្មោះឃុំ ស្រុក ខេត្តស្វាយរៀង

យើងបានដឹងថា ដូនតាយើងនិយមយករុក្ខជាតិ សត្វ ប្រវត្តិការណ៍មកដាក់ឈ្មោះឃុំ ស្រុក ខេត្ត សក្តិសមនឹងន័យមួយដោយឡែកតាមលក្ខខណ្ឌជាក់ស្តែង ភូមិសាស្ត្រមានបុគ្គលិកលក្ខណៈមួយដែលកូនខ្មែរត្រូវតែដឹង ។ ជាក់ស្តែងនៅខេត្តស្វាយរៀងមួយ គេអាចសង្កេតឃើញឈ្មោះខេត្ត-ស្រុក និង ឃុំ ចំនួន :

- ៥៧ ដោយយកតាមរុក្ខជាតិ
- ១៩ ដោយយកតាមប្រវត្តិការណ៍
- ៤ ដោយយកតាមសត្វ
- ៧ ផ្សេងៗ

ឧទាហរណ៍ :

- ឈ្មោះខេត្ត : ខេត្តស្វាយរៀង
- ឈ្មោះស្រុក : ស្រុកស្វាយរៀង
  ស្រុកស្វាយទាប
  ស្រុកស្វាយជ្រំ
  ស្រុករំដួល
  } តាមរុក្ខជាតិ ( ពិសេសស្វាយ )
  ស្រុករមាសហែក
  ស្រុកកំពង់រោទិ៍
  } តាមសត្វ
  ស្រុកចន្ទ្រា ផ្សេងៗ
- ឈ្មោះឃុំ

| ល.រ | ឈ្មោះស្រុក | ឈ្មោះឃុំ |
|---|---|---|
| ១ | ស្រុកចន្ទ្រា | ក. រុក្ខជាតិ : ព្រៃអង្គុញ ព្រៃគគីរ សំរោង ច្រេស<br>ខ. សត្វ : 0<br>គ. ប្រវត្តិការណ៍ : ប្រាសាទ ទូលស្តី បាទី បាវិត មេសថ្ងក<br>ឃ. ផ្សេងៗ : ចន្ទ្រា |
| ២ | ស្រុកកំពង់រោទិ៍ | ក. រុក្ខជាតិ : ញរ ព្រៃធំ សំឡី ស្វាយតាយាន ស្វាយតឿ ត្នោត<br>ខ. សត្វ : 0<br>គ. ប្រវត្តិការណ៍ : បន្ទាយក្រាំង ព្រះពន្លា ខ្សែត្រ រាជមន្ទីរ<br>ឃ. ផ្សេងៗ : សំយ៉ោង ថ្មី |

| | | |
|---|---|---|
| ៣ | ស្រុករំដួល | ក. រុក្ខជាតិ : បុសមន ធ្នា ចក ជ្រុងពពេល កំពង់អំពិល ពងទឹក សង្កែ ស្វាយចេក ថ្នាធ្នង់<br>ខ. សត្វ : 0<br>គ. ប្រវត្តិការណ៍ : ម៉ឺនជ័យ<br>ឃ. ផ្សេងៗ : 0 |
| ៤ | ស្រុករមាសហែក | ក. រុក្ខជាតិ : អំពិល អណ្ដូងពោធិ៍ អណ្ដូងត្របែក ជ្រៃធំ ដូង កំពង់ត្រាច គគី ក្រសាំង ម្រាម សំបួរ ត្រពាំងស្ដៅ ត្រស<br>ខ. សត្វ : 0<br>គ. ប្រវត្តិការណ៍ : អង្គប្រស្រែ សម្បត្តិមានជ័យ<br>ឃ. ផ្សេងៗ : ចន្ទ្រី មុខដារ |
| ៥ | ស្រុកស្វាយជ្រំ | ក. រុក្ខជាតិ : ចំបក់ ចេក ឈើទាល គោកព្រីង ពោធិ៍រាជ ស្វាយអង្គ ស្វាយជ្រំ ស្វាយធំ ស្វាយយា ធ្លក<br>ខ. សត្វ : ក្រោលគោ<br>គ. ប្រវត្តិការណ៍ : អង្គតាសូ បាសាក់ កំពង់ចំលង តាសួស ដូនសរ<br>ឃ. ផ្សេងៗ : គ្រួស |
| ៦ | ស្រុកស្វាយរៀង | ក. រុក្ខជាតិ : ស្វាយរៀង ព្រៃធ្លាក់ គយត្របែក ពោធិ៍តាហោ<br>ខ. សត្វ : 0<br>គ. ប្រវត្តិការណ៍ : 0<br>ឃ. ផ្សេងៗ : 0 |
| ៧ | ស្រុកស្វាយទាប | ក. រុក្ខជាតិ : ច្រកម្ទេស គគីសោម កណ្ដៀងរាយ ព្រៃតាអី សំបួរ សង្ឃ័រ ស្វាយរំពារ<br>ខ. សត្វ : រមាំងថ្កោល<br>គ. ប្រវត្តិការណ៍ : ប្រសូតិ<br>ឃ. ផ្សេងៗ : មនោរម្យ |

* តាមរឿងនិទានត១មក រំដួល > រាំដួល ( ប្រវត្តិការណ៍)

**កែវ យ៉ារ**

* * * * *

ជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជា ឆ្នាំ ១៩៩៨

# ប្រវត្តិវិទ្យា

## ការតាំងរាជធានីនៅឧដុង្គ និង ទំនាស់ផ្ទៃក្នុង

- ថ្នាក់ទី ៦
- មេរៀនទី ១៧-២៣ ៣២
- សៀវភៅសិក្សាទំព័រទី ៣០-៣១-៤០-៤១-៥៧-៥៨

**អត្ថបទជំនួយ:**

**រជ្ជកាលស្តេចខ្មែរសោយរាជ្យពីគ.ស ១៦០៣ ដល់ ១៧៥៨**

| លេខរជ្ជកាល | នាមសំរាប់រាជ្យ នាមផ្ទាល់ | កាលកំនត់រជ្ជកាល | រាជធានី | រាជវង្ស |
|---|---|---|---|---|
| ១ | បរមរាជាទី៨ ស្រីសុរិយោពណ៌ | ១៦០៣-១៦១៨ | កោះស្លាកែត លង្វែក | បុត្រព្រះបរមរាជាទី ៤ |
| ២ | ជ័យជេដ្ឋាទី ២ | ១៦១៨-១៦២៨ | ឧដុង្គ | បុត្រស្តេច ១ |
| ៣ | ធម្មរាជាទី ២ ឬរាជសំភារ ចៅពញាតូ | ១៦២៩-១៦៣៤ | កោះឃ្លោក | បុត្រស្តេច ២ |
| ៤ | អង្គទងរាជា ចៅពញានូ | ១៦៣៥-១៦៣៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៥ | បទុមរាជាទី ១ អង្គនន់ | ១៦៣៩-១៦៤១ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៦ | រាមាធិបតីទី ១ ចៅពញាចន្ទ | ១៦៤១-១៦៥៩ | ឧដុង្គ | បុត្រស្តេច ២ |
| ៧ | បរមរាជាទី ៩ អង្គសូរ | ១៦៥៩-១៦៧២ | ឧដុង្គ | បុត្រព្រះឧទ័យ |
| ៨ | បទុមរាជាទី ២ ស្រីជ័យជេដ្ឋ | ១៦៧២-១៦៧៣ | ឧដុង្គ | បុត្រស្តេច ៥ |
| ៩ | កែវហ្វាទី ២ អង្គជី | ១៦៧៣-១៦៧៥ | ឧដុង្គ | បុត្រស្តេច ៧ |

| | | | | |
|---|---|---|---|---|
| ១០[១] | ជ័យជេដ្ឋាទី ៣<br>អង្គស៊ូ ឬចៅពញាសូរ | ១៦៧៥-១៦៨៨<br>(រជ្ជកាលទី ១) | ឧដុង្គ<br>ទ្រទំជ្រឹង | បុត្រស្ដេច ៧ |
| ១១ | អ្នកម្នាងទៃ | ១៦៨៨ (៣ខែ) | ឧដុង្គ | មាតាស្ដេច ១០ |
| ១០[២] | ជ័យជេដ្ឋាទី ៣ | ១៦៨៨-១៦៩៥<br>(រជ្ជកាលទី ២) | ឧដុង្គ | បុត្រស្ដេច ៧ |
| ១២ | រាមាធិបតីទី២ ឧទ័យរាជា<br>អង្គយ៉ង | ១៦៩៥-១៦៩៦ | ឧដុង្គ | បុត្រស្ដេច ៩ |
| ១០[៣] | ជ័យជេដ្ឋាទី ៣ | ១៦៩៦-១៦៩៩<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្ដេច ៧ |
| ១៣[១] | កែវហ្វាទី ៣<br>អង្គអិម | ១៦៩៩-១៧០០<br>(រជ្ជកាលទី ១) | វាំងភាក់<br>ពោធិសាត់ | បុត្រអង្គនន់ |
| ១០[៤] | ជ័យជេដ្ឋាទី ៣ | ១៧០០-១៧០២<br>(រជ្ជកាលទី ៤) | ឧដុង្គ | បុត្រស្ដេច ៧ |
| ១៤[១] | ធម្មរាជាទី ៣ | ១៧០២-១៧០៣<br>(រជ្ជកាលទី ១) | ពោធិសាត់<br>ឧដុង្គ | បុត្រស្ដេច ១០ |
| ១០[៥] | ជ័យជេដ្ឋាទី ៣ | ១៧០៣-១៧១៦<br>(រជ្ជកាលទី ៥) | ឧដុង្គ | បុត្រស្ដេច ៧ |
| ១៤[២] | ធម្មរាជាទី ៣ | ១៧០៦-១៧០៩<br>(រជ្ជកាលទី ២) | ឧដុង្គ | បុត្រស្ដេច ១០ |
| ១៣[២] | កែវហ្វាទី ៣<br>អង្គអិម | ១៧១០-១៧២២<br>(រជ្ជកាលទី ២) | ឧដុង្គ | បុត្រអង្គនន់ |
| ១៥[១] | សត្ថាទី ២<br>អង្គជី | ១៧២២-១៧២៩<br>(រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្ដេច ១៣ |
| ១៣[៣] | កែវហ្វាទី ៣-ជ័យជេដ្ឋា<br>អង្គអិម | ១៧២៩ (៧ខែ)<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រអង្គនន់ |
| ១៥[២] | សត្ថាទី ២-បរមរាជា<br>អង្គជី | ១៧២៩-១៧៣៧<br>(រជ្ជកាលទី ២) | ឧដុង្គ<br>លង្វែក | បុត្រស្ដេច ១៣ |
| ១៤[៣] | ធម្មរាជាទី ៣-ជ័យជេដ្ឋា | ១៧៣៨-១៧៤៧ | ឧដុង្គ | បុត្រស្ដេច ១០ |

| | | | | |
|---|---|---|---|---|
| | | (រជ្ជកាលទី ៣) | | |
| ១៦ | ធម្មរាជាទី ៤<br>អង្គអិម | ១៧៤៧ (១ឆ្នាំ) | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧[១] | រាមាធិបតីទី ៣<br>អង្គទង | ១៧៤៧-១៧៤៨<br>(រជ្ជកាលទី ១) | ឧដុង្គ | បុត្រស្តេច ១២ |
| ១៥[៣] | ព្រះសត្ថាទី ២<br>អង្គជី | ១៧៤៩<br>(រជ្ជកាលទី ៣) | ឧដុង្គ | បុត្រស្តេច ១៣ |
| ១៨ | ស្រីជ័យជេដ្ឋ<br>អង្គស្ងួន | ១៧៤៩-១៧៥៥ | ឧដុង្គ | បុត្រស្តេច ១៤ |
| ១៧[២] | រាមាធិបតីទី ៣<br>អង្គទង | ១៧៥៦-១៧៥៧<br>(រជ្ជកាលទី ២) | ឧដុង្គ<br>ពោធិសាត់ | បុត្រស្តេច ១២ |
| ១៩ | នារាយណ៍រាជាទី ២<br>ឧទ័យរាជា អង្គតន់ | ១៧៥៨-១៧៧៥ | ឧដុង្គ | ចៅស្តេច ១៨ |

ដកស្រង់ដោយ : **កែវ សុបុរិន្ទ**
សាស្ត្រាចារ្យចិត្តវិទ្យា-អប់រំ
នៅមហាវិទ្យាល័យគរុកោសល្យ

xxxxxxx

- ១០ វិច្ឆិកា ១៩១១ : បញ្ជារបស់ស្តេច
  - ភាសាខ្មែរត្រូវបានសិក្សានៅគ្រប់វត្តទាំងអស់
  - ការសិក្សាចាំបាច់ចាប់ពីរយៈពេល ៨ឆ្នាំ
- ០៨ វិច្ឆិកា ១៩៤៩ : ការចុះហត្ថលេខាសច្ចាលើសន្ធិសញ្ញាឯករាជ្យ
- ២៩ កញ្ញា ១៩៥៤ : ការចុះហត្ថលេខាលើសន្ធិសញ្ញានៅទីក្រុងប៉ារីសទទួលស្គាល់ឡើងវិញនូវលក្ខន្តិកៈអន្តរជាតិមេគង្គ ។
- ២៤ កញ្ញា ១៩៥៨ : សម្តេចនរោត្តម សីហនុ ប្រកាសអព្យាក្រឹតភាពនៃប្រទេសកម្ពុជា នៅសភាទាំងមូលនៃអង្គការសហប្រជាជាតិ ។
- ២០ ធ្នូ ១៩៦៩ : សម្ពោធខ្សែរថភ្លើងពីភ្នំពេញទៅកំពង់សោម ។

ត្រឹង ងា : ប្រវត្តិសាស្ត្រខ្មែរភាគ ២

# គំនូរ

## វិធីបង្រៀនគំនូរ(ត)

ដោយលោក : ប៉ាន់ ត្រា

ខាងក្រោមនេះ ជាគំនូររូបភាពដទៃខ្លះទៀត ដែលរចនាឡើងដោយគំនូសត្រង់ ៣ បែបនេះដែរ ។

វិធីសាស្ត្រដែលត្រូវប្រើក្នុងការគូររូបភាពក៏ដោយ ផ្ទាំងតុបតែងលំអក៏ដោយ សុទ្ធតែប្រើរបៀប "គំនូរគូរតាម" ទាំងអស់ ។

(អោយសិស្សដាក់ពណ៌ដោយសេរី)

វត្ថុទី ១ វត្ថុទី ២ វត្ថុទី ៣





## ផ្ទាំងតុបតែងលំអ

ត្រូវណែនាំសិស្សអោយយកគំនូសត្រង់ទាំង ៣ បែបនេះទៅគូសផ្សំលំអក្នុងផ្ទៃការេ ដើម្បីយកទៅតំរៀបអោយកើតទៅជាខ្សែតុបតែងលំអ ។

ខាងក្រោមនេះគឺជាផ្ទាំងតុបតែងលំអក្នុងផ្ទៃការេ ជាឧទាហរណ៍ ÷

(អោយសិស្សដាក់ពណ៌ដោយសេរី)

វគ្គទី ១ វគ្គទី ២ វគ្គទី ៣

១.

២.

៣.

៤.

៥.



៦. 

## ខ្សែគុបតែងលំអ

បើគេយកផ្ទាំងគុបតែងលំអក្នុងផ្ទៃការេខាងលើនេះ ទៅតំរៀបបន្តអោយស្មើគ្នាវែងទៅ និង បានទៅជាខ្សែគុបតែងលំអប្រកបដោយសោភ័ណភាព ។

ខាងក្រោមនេះ គឺជាខ្សែគុបតែងលំអរចនាឡើងដោយយកផ្ទាំងគុបតែងលំអខាងលើមកគួរតំរៀបបន្តគ្នា ។




គំនូរជារូបភាព ជាផ្ទាំង និង ខ្សែគុបតែងលំអទាំងអស់ខាងលើដែលដាក់អោយសិស្សគូរនេះ គឺជាការរំលឹកនូវប្រយោជន៍របស់គំនូសត្រង់ទាំង ៣ បែប ដែលសិស្សបានរៀនហើយនៅថ្នាក់ទី ១ ។

(នៅមានត)

**"ពីអ្នកវាស់ដី បានកកើតរេខាគណិត"**

*(De l'arpenteur est née la géométrie)*

# ភូមិវិទ្យា

## គូរផែនទីប្រទេសកម្ពុជា

- ថ្នាក់ទី ៦
- សៀវភៅសិស្ស ទំព័រទី ១១
- សៀវភៅគ្រូ ទំព័រទី ៣០ "វាយតំលៃ"

**អត្ថបទជំនួយ:**

១. តាមផែនទីកម្ពុជាដែលទើបគូររួច តើអ្នកឃើញថាប្រទេសយើងមានលក្ខណៈសម្បត្តិអ្វីខ្លះសំរាប់អំណោយផលផ្នែកសេដ្ឋកិច្ច ?

<u>ចំលើយ</u> : លក្ខណៈអំណោយផលផ្នែកសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមាន : សមុទ្រ បឹងទន្លេសាបនៅកណ្តាលផ្ទៃប្រទេស ទន្លេមេគង្គ ទន្លេតូច និង ទន្លេធំ ។

២. បើសិនជាបឹងទន្លេសាបស្ងួត តើនឹងមានហេតុការណ៍អ្វីខ្លះកើតឡើង ?

<u>ចំលើយ</u> : បើសិនជាបឹងទន្លេសាបរីងស្ងួត ត្រីលែងសំបូរ ខេត្តនៅតំបន់ទំនាបកណ្តាល និង ខេត្តភាគខាងត្បូង និង ខាងកើតប្រទេសនឹងរងគ្រោះទឹកជំនន់ជារៀងរាល់ឆ្នាំ បណ្តាលអំពីទឹកភ្លៀង និង ទឹកទន្លេមេគង្គ ។

៣. ដើម្បីកុំអោយហេតុការណ៍អាក្រក់នេះកើតឡើង តើត្រូវធ្វើដូចម្តេច ?

<u>ចំលើយ</u> : ដើម្បីកុំអោយហេតុការណ៍អាក្រក់នេះកើតឡើងបាន ត្រូវការពារបឹងទន្លេសាបកុំអោយរីងស្ងួត ដោយបូមដីបាតបឹងចេញ មិនត្រូវដាក់សំរាស់ចាប់ត្រីក្នុងបឹង មិនត្រូវកាប់ព្រៃលិចទឹក ហើយត្រូវដាំព្រៃលិចទឹកឡើងវិញ ។

**កែវ សុបុរិន្ទ**
សាស្ត្រាចារ្យចិត្តវិទ្យា-អប់រំ
នៅមហាវិទ្យាល័យគរុកោសល្យ

❖❖❖❖❖❖❖

"បៃតង ស្អាត រីករាយ"
*(Green Clean Happy)*
ពាក្យស្លោកបរិស្ថាន

# គណិតវិទ្យា

## វិធីបូក ដក

- ថ្នាក់ទី ៤
- សៀវភៅសិស្ស ទំព័រទី ៨

**<u>អត្ថបទជំនួយ:</u>**

**<u>ចំណោទទី១:</u>** នៅពេលវិស្សមកាល តារា ភារី និង វីរៈបានកត់ត្រាចំណាយរៀង១ខ្លួនដូចខាងក្រោម :

| | សប្ដាហ៍ទី ១ | សប្ដាហ៍ទី ២ | សប្ដាហ៍ទី ៣ | |
|---|---|---|---|---|
| តារា | ៥៣០០៛ | ៤៥០០៛ | ១០៣០០៛ | ៤........................ |
| ភារី | ៣៨០០៛ | ៧៨០០៛ | ៦៩០០៛ | ៥........................ |
| វីរៈ | ១២២០០៛ | ៣៧០០៛ | ១២៨០០៛ | ៦........................ |
| | ១........................ | ២........................ | ៣........................ | ៧........................ |

ក. ចូរបំពេញតារាង ។

ខ. តើអ្នកទាំង៣នាក់ចាយអស់ប៉ុន្មាន នៅសប្ដាហ៍ទី ១ ?

គ. តើតារាចាយអស់ប្រាក់ប៉ុន្មាន នៅពេលវិស្សមកាលនេះ ?

**ចំលើយ:** ១/. ២១៣០០៛ ២/. ១៦០០០៛ ៣/. ៣០០០០៛

៤/. ២០១០០៛ ៥/. ១៨៥០០៛ ៦/. ២៨៧០០៛ ៧/. ៥៧៣០០៛

**<u>ចំណោទទី២:</u>** រោងកុនគីរីរម្យ បានស្រង់ស្ថិតិអ្នកចូលទស្សនាដូចខាងក្រោម :

| | សៅរ៍ | ច័ន្ទ | អង្គារ | ពុធ |
|---|---|---|---|---|
| មនុស្សធំ | ១៨១៥ | ៩២៨ | ៣........................ | ៦៩៣ |
| កុមារ | ៧២៩ | ២........................ | ៥៧៩ | ៤........................ |
| សរុប | ១........................ | ១៩៤៥ | ១០៨៥ | ១៧៥០ |

ចូរបំពេញចន្លោះ ។

**ចំលើយ:** ១/. ២៥៤៤៛ ២/. ១០១៧៛ ៣/. ៥០៦៛ ៤/. ១០៥៧៛

**<u>ចំណោទទី៣:</u>** បញ្ញាមានទំងន់ ៤២.៥០គ.ក្រ ដេតមានទំងន់ ៥១ គ.ក្រ។ តើអ្នកទាំងពីរមានទំងន់ខុសគ្នាប៉ុន្មានគីឡូក្រាម ?

**ចំលើយ:** ៨.៥ គ.ក្រ

<u>**ចំណោទទី៤:**</u> ឪពុកមានអាយុ ៣៥ ឆ្នាំ នៅពេលដែលកូនទើបនឹងកើត ។ នៅពេលដែលកូនអាយុបាន ១៨ឆ្នាំ តើឪពុកមានអាយុប៉ុន្មាន ?

**ចំលើយ:** ៣៥ + ១៨ = ៥៣ ឆ្នាំ

<u>**ចំណោទទី៥:**</u> លោកឧកញ៉ា នូ កន បានរស់នៅតាំងពីឆ្នាំ ១៨៧៤ ដល់ ឆ្នាំ ១៩៤៧ ។ តើជីវិតរស់នៅរបស់គាត់មានរយៈពេលប៉ុន្មានឆ្នាំ ?

**ចំលើយ:** ១៩៤៧ - ១៨៧៤ = ៧៣ ឆ្នាំ

<u>**ចំណោទទី៦:**</u> សម្តេចព្រះសង្ឃរាជ ជួន ណាត ព្រះអង្គទ្រង់មានព្រះជន្មរស់នៅតាំងពីឆ្នាំ ១៨៨៣ រហូតដល់ឆ្នាំ ១៩៦៨ ។ តើព្រះជន្មរស់នៅរបស់ព្រះអង្គមានរយៈពេលប៉ុន្មានព្រះវស្សា ?

**ចំលើយ:** ៨៥ ព្រះវស្សា

<u>**ចំណោទទី៧:**</u> សាលីនបានធ្វើបាក់ចុងបន្ទាត់ខុបដេសីម៉ែត្ររបស់នាង ។ ដើម្បីវាស់ខ្មៅដៃរបស់នាងដាក់ចុងខ្មៅដៃម្ខាងនៅត្រង់លេខ ១១ស.ម និង ចុងម្ខាងទៀតរត់ដល់លេខ ១៩ ស.ម ។ តើខ្មៅដៃរបស់នាងមានប្រវែងប៉ុន្មាន ?

**ចំលើយ:** ៨ ស.ម

<u>**ចំណោទទី៨:**</u> យន្តហោះមួយហោះក្នុងរយៈកំពស់ ៩៥០០ម ។ រួចអ្នកបើកបរបានបន្ថែមកំពស់ ៣០០ម បន្ទាប់មកគាត់បានចុះមកវិញចំនួន ៤៥០ម មកវិញ ។ តើឥឡូវវាស្ថិតនៅក្នុងរយៈកំពស់ប៉ុន្មាន ?

**ចំលើយ:** ៩៣៥០ ម

<u>**ចំណោទទី៩:**</u> ភ្នំអេវើរេសមានកំពស់៨៨៤៨ម ។ ភ្នំសនៅប្រទេសបារាំងមានកំពស់ ៤៨០៧ម ។ តើភ្នំណាខ្ពស់ជាង? ហើយខ្ពស់ជាងប៉ុន្មាន ?

**ចំលើយ:** ភ្នំអេវើរេសខ្ពស់ជាង ៤០៤១ ម

<u>**ចំណោទទី១០:**</u> ខាងក្រោមនេះជាចំណោទ២។ ចូរដោះស្រាយចំណោទដែលត្រូវធ្វើប្រមាណវិធីបូក ដើម្បីរកចំលើយឃើញ។

<u>**ចំណោទ"ក":**</u>

ព្រឹកមិញមុននឹងចេញដំណើរ វណ្ណាបានមើលលេខក្នុងប្រដាប់វាស់ល្បឿនរថយន្តរបស់គាត់ គាត់ឃើញលេខ ៤៤២៧៣គ.ម ។ នៅពេលទៅដល់ទីដៅ គាត់ឃើញលេខ ៤៤៩០៣គ.ម ។ តើថ្ងៃនេះវណ្ណាបើកបានប៉ុន្មានគីឡូម៉ែត្រ ?

<u>**ចំណោទ"ខ":**</u>

ប្រដាប់វាស់ល្បឿនរថយន្តរបស់លោក សារី ចង្អុលលេខ ៧៥៧៣២ គ.ម ។ តើប្រដាប់ល្បឿនចង្អុលលេខប៉ុន្មាន នៅពេលលោកសារីបើកបាន ២៦៨គ.ម ?

**ចំលើយ:** - ចំណោទដែលខ្ញុំត្រូវដោះស្រាយ គឺចំណោទ "ខ"

- ចំលើយរបស់ខ្ញុំគឺ : ៧៥៧៣២ + ២៦៨ = ៧៦០០០

**ចំណោទទី១១:** ខ្ញុំអានសៀវភៅប្រលោមលោកមួយយ៉ាងជក់ចិត្ត ។ មកដល់ទំព័រចុងក្រោមទៅហើយ ខ្ញុំនៅតែពុំដឹងថាអ្នកណាជាតួឯកនៅឡើយ ។ ប្រលោមលោកនេះ មាន១៥៦ទំព័រ ហើយខ្ញុំបានអាន ១៣៧ទំព័រទៅហើយ ។ តើនៅសល់ប៉ុន្មានទំព័រទៀតទើបចប់ ?

► **សំនួរ:** តើខ្ញុំត្រូវធ្វើប្រមាណវិធីណាដើម្បីឆ្លើយនឹងសំនួរនេះ ។

ចូរគូសសញ្ញា ក្នុងប្រអប់ខាងក្រោម ។

☐ ប្រមាណវិធីបូក ☐ ប្រមាណវិធីដក

**ចំលើយ:** ☐ ប្រមាណវិធីបូក

☑ ប្រមាណវិធីដក

**ចំណោទទី១២:** នេះជាតារាងចំណូល-ចំណាយរបស់នេរិទ្ធ

| ល.រ | | រាយមុខចំណូល-ចំណាយ | ទឹកប្រាក់ចំណូល | ទឹកប្រាក់ចំណាយ | សល់ |
|---|---|---|---|---|---|
| ចូល | ចេញ | | | | |
| ១ | | ម្ដាយឪពុកផ្ដត់ផ្ដង | ៣៥០០៛ | | ៣៥០០៛ |
| | ១ | ស្រស់ស្រូបពេលព្រឹក | | ១៥០០៛ | ២០០០៛ |
| ២ | | អំណោយពីបងប្រុស | ១៥០០៛ | | ៣៥០០៛ |
| | ២ | ទិញសៀវភៅមើល | | ១៥០០៛ | ២០០០៛ |
| ៣ | | ការឧបត្ថម្ភបន្ថែមរបស់ម្ដាយឪពុក | ២០០០៛ | | ៤០០០៛ |
| | ៣ | ទិញប៊ិច | | ៥០០៛ | ៣៥០០៛ |
| សរុប | | | ១................ | ២................ | ៣................ |

តើនេរិទ្ធមានចំណូលប៉ុន្មាន ? ចំណាយអស់ប៉ុន្មាន ? សល់ប៉ុន្មាន ?

**ចំលើយ:** ១/. ៧០០០៛ ២/. ៣៥០០៛ ៣/. ៣៥០០៛

លោកស្រី : **ឈិត សារឿត**

អធិការបង្រមសិក្សា នៅមហាវិទ្យាល័យគរុកោសល្យ

# គណិតវិទ្យា

## ត្រីកោណ

- ថ្នាក់ទី ៦
- មេរៀនទី ១១
- សៀវភៅសិស្សទំព័រ ១១៧-១១៩

### អត្ថបទជំនួយ:

ចូររាប់ឈ្មោះត្រីកោណសមបាត ត្រីកោណកែង ចតុកោណកែង ។ មានស្គាល់រូបអ្វីផ្សេងទៀតទេ ? ឈ្មោះអ្វី?




រូបផ្សេង..................................................

..................................................

ត្រីកោណកែង..................................................

..................................................

ចតុកោណកែង..................................................

..................................................

ត្រីកោណសមបាត..................................................

### ចំលើយ

- រូបផ្សេង : AEFJ-ACHJ-CEFH-ACFH : ប្រលេឡូក្រាម
- ត្រីកោណកែង : AIJ, AHI, ABH, BCH, CGH, CFG, CDF ,DEF
- ចតុកោណកែង : ABHI, ACGI, BCGH, BDFH, CDFG, ADFI
- ត្រីកោណសមបាត : AHJ, ACH, CFH, CEF

**កែច យ៉ារ**




## ការអប់រំនៅមត្តេយ្យសិក្សា

(បទកាកគតិ)

មត្តេយ្យពូតផ្ដុំ ចំណេះមូលជុំ អប់រំបុត្រភ្ញា មានរៀនមានលេង
រួមជួបជុំគ្នា ឱពៅពុំងា ត្រូវខំសិក្សា ។
សាលាមត្តេយ្យ ជួយក្មេងដល់វ័យ អោយមានសក្ដា មានចំណេះដឹង
ទុកគ្រាន់សិក្សា ពូកែហានក្លា ពេលទៅបឋម ។
ទៅរៀនមត្តេយ្យ ក្មេងទាំងប្រុសស្រី បានការអប់រំ ចំណេះសីលធមិ
ប្រសើរសក្ដិសម កូន១ខិតខំ ក្លាយជាពលល្អ ។
បើញាតិដឹងហើយ សូមកុំកន្ដើយ ជួយកូនបវរ អោយបានទៅរៀន
ដោយចិត្តស្មោះសរ កុមារអបអរ បានការអប់រំ ។
លុះកូនដឹងក្ដី មេបាអស់ភ័យ ព្រោះអីមាសមុំ នាងមានឫកពា
ចរិយារម្យទម នៅក្នុងភូមិឃុំ គេស្នេហ៍គ្រប់គ្នា ។

លោកស្រី : ឡោក់ សុលីជា

“ បើនេះមាន នោះក៏ត្រូវមានដែរ
បើនេះគ្មាន នោះក៏គ្មានដែរ
បើនេះស្លាប់ នោះក៏ត្រូវស្លាប់ដែរ ”

ទស្សនទានជីវិតរបស់ព្រះពុទ្ធ

# ច្បាប់ត្រីនេតិ

(បទកាកគតិ)

..............................................................................................................

..............................................................................................................

មួយកុបុត្តំ នាសតិធនំ បទបន្ទែថា បើមានកូនកាច
កំណាចហើយណា សឹងវិនាសប្រា- កដគឺសន្តាន ។
មួយកុភូមំ នាសតិធនំ វិនាសធនធាន នៅភូមិអាក្រក់
នោះនឹងកើតមាន ព្យាធិបៀតប្រាណ ពិតពុំប្រពៃ ។
មួយកុគេហំ នាសតិជិវិ បន្ទែនេះនៃ នៅផ្ទះអាក្រក់
នឹងកើតហីនហៃ ប្រាជ្ញាញាណញ្ញៀយ្យ អាប់ឥតមង្គល ។
កើតកេ្តីអាប់យស ដោយនូវពាក្យមនុស្ស គេដើរមកយល់ ហើយគេដឹងថា
ផ្ទះអាក្រក់សល់ កើតអពមង្គល ដោយពាក្យគេថា ។
ឯសុមន្ត្រី ដោយអាថិបាលី វុឌ្ឍិរាជា បើមុខមន្ត្រី
មែនមានប្រាជ្ញា ដឹងអស់អធ្យា- ស្រ័យគ្រប់ប្រការ ។
តម្រង់មហាក្សត្រ សោយរាជសម្បត្តិ ក្សេមក្សាន្តភពការ អស់រាស្ត្រមណ្ឌល
សកលបរិពារ សឹងឥតរង្គាល ដល់តិចឡើយហោង ។
ឯសុបុត្តំ វុឌ្ឍិកុលំ ថាបើកូនផង មែនមានគំនិត
ល្អឥតឯហ្មង សឹងចំរើនបង ប្អូនសាច់សន្តាន ។
ឯសុភូមំ វុឌ្ឍិធនំ ថាទោះភូមិស្ថាន ល្អហើយនោះនឹង
ចំរើនធនធាន សារពើសឹងបាន ដូចចិត្តប្រាថ្នា ។
ឯសុគេហំ វុឌ្ឍិជិវិ ថានៅគ្រឹហា ល្អហើយនោះនឹង
ចំរើនប្រាជ្ញា សារពើប្រាថ្នា ពិតពុំកម្រ ។
ទោះអ្នកផងដើរ គេសឹងសរសើរ ថាផ្ទះនោះល្អ ចំរើនសួស្តី
អំពីមាត់ម- នុស្សផងគេសរ- សើរផ្ទះនោះនៃ ។

..............................................................................................................

..............................................................................................................

៚៚៚៚៚៚៚

# បទដ្ឋាននៃខ្នាតក្រដាស

ក្រដាស $A_4$ ជាទំរង់ក្រដាសដែលគេនិយមប្រើប្រាស់ជាងគេ ជាពិសេសសំរាប់រាល់លិខិតស្នាមនៃការងាររដ្ឋបាលទូទៅ។

តើ $A_4$ ជាអ្វី ?

ក្រដាស $A_4$ ជាក្រដាសដែលមានទំហំខ្នាត ២៩៧ម.ម x ២១០ម.ម ។ ទំហំខ្នាតនេះ គឺជានិយាមអន្តរជាតិ (norme internationale) ខាងគំនូរបច្ចេកទេស( គំនូរឧស្សាហកម្ម, គំនូរស្ថាបត្យកម្ម...) ដែលគេបានសំរេចកំនត់ចេញមកអំពីខ្នាត $A_0$ ស្មើនឹងមួយម៉ែត្រការេ ។

$A_0$ មានទំហំ ១១៨៩ x ៨៤១ ស្មើនឹង $0,999949 m^2$ ។ ចេញពី $A_0$ នេះ មានទំហំខ្នាតបួនទៀតគឺ $A_1$, $A_2$, $A_3$ និង $A_4$ ( ប្រព័ន្ធអាល្លឺម៉ង់មាន $A_5$ ) ។

គេបានទំហំ $A_1$ ដោយយក $A_0$ កាត់ជាពីរចំនែកស្មើគ្នា តាមរយៈទទឹង ។ គេធ្វើរបៀបនេះជាបន្តទៀតគេបាន $A_2$, $A_3$, $A_4$ ( និង $A_5$ ) ។

| | | | | |
|---|---|---|---|---|
| $A_0$ | = | 1189 | x | 841 |
| $A_1$ | = | 594 | x | 841 |
| $A_2$ | = | 594 | x | 420 |
| $A_3$ | = | 297 | x | 420 |
| $A_4$ | = | 297 | x | 210 |
| $A_5$ | = | 148 | x | 210 |




បើគេកំនត់ថាអោយប្រើក្រដាសទំហំ $A_4V$ ឬ $A_4H$ នោះ បានន័យថា :

- V = vertical បញ្ឈរ
- H = horizontal ផ្ដេក

✧ តើ $A_0$ មួយមាន $A_5$ ប៉ុន្មាន ?

( ចំលើយ : ៣២ $A_5$ )




យស់ អ៊ាច

ఠఠఠఠఠఠఠ



# ព្យាង្គតំរួត

ពាក្យទាំងឡាយ មានពាក្យខ្លះកើតឡើងពីព្យាង្គរាយ ខ្លះពីព្យាង្គតំរួត ។ ព្យាង្គតំរួត កើតពីពាក្យពីរព្យាង្គ ជា ធម្មតាកាលណាព្យាង្គទាំងពីរនោះ :

- ព្យាង្គខាងដើមមានអក្សរប្រកប
- អក្សរប្រកបនោះជាអក្សរនៅក្នុងវគ្គជាមួយគ្នានឹងព្យាង្គបន្ទាប់
- ព្យាង្គទាំងពីរ បើញែកគ្នាចេញ បើប្រែក៏ប្រែខុសពីការសំដៅរបស់ពាក្យនោះ ។ ឧទាហរណ៍ : សន្ទូច > សន់+ទូច គ្មានន័យ, បណ្ដើរ > បន់+ដើរ មានន័យខុសពីការសំដៅរបស់បញ្ញត្តិនោះ ។

ក្នុងភាសាខ្មែរអាចត្រួតបាន លុះតែអក្សរប្រកបរបស់ព្យាង្គដើម និង អក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់ : អក្សរទី ៥ ត្រូវដាក់លើអក្សរទាំង៤ខាងដើមវគ្គ លើកលែងតែពាក្យបាលីដែលអក្សរទី១នៅលើទី២ ទី៣នៅលើទី៤ ។ ជាក់ស្ដែង ÷

- អក្សរ "ង" ត្រូវត្រួតនៅលើអក្សរ ក.ខ.គ.ឃ ។ ឧទាហរណ៍ : អង្ករ បង្ការ បង្ខំ បង្ហូច ដង្កុំ សង្ឃឹម...។
- អក្សរ "ញ" ត្រូវនៅលើ ច.ឆ.ជ.ឈ រឺលើ ញ ខ្លួនឯង ។ ឧទាហរណ៍ : កញ្ចាច់ចេក ចិញ្ចៀង កញ្ជា កញ្ជែត បញ្ចា បញ្ចាក់ បញ្ឈរ បញ្ចើ ...។
- អក្សរ "ណ" ត្រូវនៅលើអក្សរ ដ (ឋ.ឌ.ឍ មិនមែនពាក្យប្រើក្នុងភាសាខ្មែរ) ។ ឧទាហរណ៍ : ដណ្ដាំ បណ្ដោយ បណ្ដែត ...។
- អក្សរ "ន" ត្រូវនៅលើអក្សរ ត.ថ.ទ.ធ ។ ឧទាហរណ៍: បន្ត កន្ទាំង បន្ថែម បន្ថយ បន្ទុក បន្ទប់ ចន្ទូរ បន្ទូរ..។
- អក្សរ "ម" ត្រូវត្រួតនៅលើ ប.ផ.ព.ភ ។ ឧទាហរណ៍ : សម្បុរ សម្ភព ...។

ចំនែកអក្សរសេសវគ្គអាចត្រួតនៅក្រោមតួអក្សរណាក៏បាន ។ ឧទាហរណ៍ : ចង្រៃ ពន្យារ ពន្លា សន្លប់ បង្អើរ សន្សំ ...។

• ចំពោះការត្រួតនឹងអក្សរ "ម" គួរយើងកត់សំគាល់ដោយយោងទៅលើការប្រើរស្សសញ្ញា (បន្តក់) ក្នុងការអានកំបុតខ្លី ÷

ក. អក្សរ "ង" : ស្រះ ា ប្រកបនឹងខ្យល់ ង មិនត្រូវប្រើបន្តក់ពីលើឡើយ ត្រូវប្រើនិគ្គហិត ( ំ ) ជំនួសវិញ ។

ឧទាហរណ៍ : អាង → អាង់ ⇒ អាំង

ខ. អក្សរ"ម" ក៏ស្របនឹងប្រការខាងលើនេះដែរ ។ ឧទាហរណ៍ : សម់ > សំ ...

• ប្រការគួរកត់សំគាល់មួយទៀត គឺក្នុងករណីប្រកបនឹងស្រៈបង្អប់(ស្រះ៑) នៅពេលគ្រួតព្យាង្គដើមរបស់ពាក្យត្រូវអានខ្លីកំបុតដូចជាមានបន្តក់នៅក្នុងស្រាប់ ឧទាហរណ៍ : កង្កែប > កង់ + កែប, កន្ទក់ > កន់ + ទក់, បញ្ចាក់ > បញ់ + ជាក់...។

ដូចនេះ យោងតាមចំនុច"ខ" និងការអានព្យាង្គដើមរបស់ពាក្យបែបនោះទើបអក្សរ"ម"មិនត្រូវគួរបានគ្រួតលើអក្សរទាំង ៤ ដូចវគ្គដទៃ ។

ក្នុងករណី "ម" មិនត្រូវទទួលបន្តក់បាននោះ យើងត្រូវអានពាក្យមានព្យាង្គតំរួតនឹងអក្សរ"ម"ដូចម្ដេច ÷ ឧទាហរណ៍ : តម្រូវ > តម + រ៉ូវ រឺតំ + រ៉ូវ, សម្លាប់ > សម + ឡាប់ រឺសំឡាប់, ចម្បាំង > ចម + បាំង រឺចំបាំង ...។

និយាយដល់ត្រង់នេះ លោកអ្នកច្រើនពេបជ្រាយហើយពោលថា ខ្មែរមិនចេះអានខ្មែរដូចម្ដេច គេធ្លាប់អស់ទៅហើយ ។ ចុះយើងមិនគិតថា ភាសាខ្មែរត្រូវបានបរទេសរៀនដែររឺទេ ។ គួរអនុវត្តទៅតាមក្បួនវេយ្យាករណ៍ឯកភាពមួយ ។

ជារួម ប្រសិនបើយើងមានក្បួនវេយ្យាករណ៍ហើយនោះ គួរយើងខិតខំបំពេញបំនងរៀមច្បងយើង ពិសេសសម្ដេចសង្ឃ ជួន ណាត ដែលព្រះអង្គពុំទាន់បានពេញព្រះហប្ញទ័យនឹងវចនានុក្រមខ្មែរនៅឡើយ "គ្រាន់តែជាក្រាលគ្រួសក្រហមនៅឡើយ"ដោយអនុវត្តអោយបានត្រឹមត្រូវដូចជា ក្នុងការគ្រួត : យើងគួរសរសេរ : ដូច្នេះ >ដូចនេះ, ដូច្នោះ > ដូចនោះ, ប៉ុណ្ណេះ > ប៉ុននេះ ..... ហើយក៏យើងអាចមានលើកលែងខ្លះៗដ៏តិចតួចបានហើយដូចជា ប៉ុន្មាន... ។

**ម៉ុម សុម៉ាច**

បណ្ណារក្សនៅមហាវិទ្យាល័យគរុកោសល្យ

**ការកែតំរូវ:**

* ទស្សនាវដ្ដីគ្រូបង្រៀនលេខ ១៤

| ទំព័រ | បន្ទាត់ | កំហុសឆ្គង | កែតំរូវ |
|---|---|---|---|
| ៣៤ | ១ + ២ | ...(ដេក យល់ រៀន រឺង សុទ្ធ)...គឺជាកិរិយាសុទ្ធ រឺគុណនាម | ...(ដេក យល់ រៀន រឺង សុទ្ធ)...គឺជាកិរិយាហេតុ |

* ទស្សនាវដ្ដីគ្រូបង្រៀនលេខ ១៦

| ទំព័រ | បន្ទាត់ | កំហុសឆ្គង | កែតំរូវ |
|---|---|---|---|
| ៣៧ | ទី៣ ពីក្រោមឡើងលើ | ឆ្កង | ឆ្លង |

វេយ្យាករណ៍ : ពៅ អ៊ុំ

# ភូមិអន្លង់រមៀត

បើយើងធ្វើដំណើរចេញពីភ្នំពេញតាមផ្លូវជាតិលេខ៣ចំងាយ២៥គីឡូម៉ែត្រ យើងនឹងទៅដល់ស្ទឹងមួយជាដៃទន្លេបាសាក់ គឺស្ទឹងកំពង់កន្ទួត[១] ហើយភូមិដែលនៅខាងត្បូងជាប់មាត់ស្ទឹងហៅថា ភូមិកំពង់ទួល ។ ពេលយើងធ្វើដំណើរទៅដល់ភូមិកំពង់-ទួលនេះ យើងបត់ឆ្វេងដៃតាមផ្លូវទៅផ្សារកំពង់កន្ទួតចំងាយ១គីឡូម៉ែត្រ យើងនឹងឃើញខ្លោងទ្វារមួយនៅខាងស្ដាំដៃ គឺជាខ្លោងទ្វារវត្តអន្លង់រមៀត ។ ផ្លូវចូលវត្តមានក្រាលកៅស៊ូ[២] រហូតដល់វត្តអមដោយផ្ទះរបស់ប្រជាពលរដ្ឋ និង ដើមឈើមានម្លប់ត្រឈឹងត្រឈៃគួរអោយចង់ធ្វើដំណើរពន់ពេក ។ ប្រជាពលរដ្ឋដែលរស់នៅអមសងខាងផ្លូវចូលវត្តអន្លង់រមៀតរហូតដល់វត្តទួលសាលា និង វត្តអង្គសេរីហៅវត្តថ្មី ដែលមានចំងាយប្រហែល ២ គីឡូម៉ែត្រ នៅជិតបណ្ដោយផ្លូវជាតិលេខ ៣ គឺជាអ្នកភូមិអន្លង់រមៀត ។



ភូមិអន្លង់រមៀត ជាភូមិមួយនៅក្នុងឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ហើយជាភូមិដែលមានឈ្មោះបោះសំលេងលើព្រះរាជាណាចក្រកម្ពុជា តាំងពីទសវត្សទី ៦០ ពីព្រោះភូមិនេះត្រូវបានសម្ដេច នរោត្ដម សីហនុ រៀបចំជាភូមិគំរូ ចាប់តាំងពីឆ្នាំ១៩៦១មកម្ល៉េះ ។ ដោយសារស្នាព្រះហស្ថរបស់សម្ដេចឪក្នុងការអភិវឌ្ឍ ភូមិអន្លង់រមៀតបានក្លាយជាទីរមណីយដ្ឋានមួយដែលមានភ្ញៀវជាតិ និង អន្ដរជាតិមកធ្វើទស្សនកិច្ច និងកំសាន្ដជាហូរហែក្នុងទសវត្សទី ៦០នេះ ។ ក្នុងទសវត្សនេះ ភូមិអន្លង់រមៀតមានផ្លូវកាត់ខ្វាត់ខ្វែងតាមផ្ទះនីមួយៗមានបង្គន់អនាម័យ និង មានការសំអាតស្អាតជានិច្ចនៅជុំវិញគេហដ្ឋាន ។ នៅបរិវេណខាងជើងជាប់របងវត្តអន្លង់រមៀតមានមណ្ឌលអភិវឌ្ឍន៍មួយ ។ នៅក្នុងមណ្ឌលអភិវឌ្ឍន៍នេះ មានមន្ទីរឃោសនាមួយយ៉ាងធំសំរាប់បិទរូបថតសកម្មភាពរីកចំរើនគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផលិតផលដែលប្រជារាស្ដ្រផលិតបាន ។ នៅខាងលិចនៃមន្ទីរឃោសនានេះ មានមន្ទីរពេទ្យមួយដែលមានគិលានុប្បដ្ឋានប្រចាំការជាប់ជានិច្ច ។ នៅខាងជើងនៃមន្ទីរពេទ្យនេះបន្ដិច មានរោងចក្រធ្វើស្ករសមួយដែលមានផ្លាកសញ្ញានៅលើស្លោងផ្លាស្ទិចថា : ស្ករសអន្លង់រមៀត ។ ខាងកើតនៃរោងចក្រនេះ មានទីធ្លាសំរាប់កុមារកំសាន្ដដូចជាទោង...ជាដើម ។

ខាងកើតនៃកន្លែងកំសាន្ដរបស់កុមារមានអាគារពីរទន្ទឹមគ្នាគឺ ÷ "សហករណ៍យើង" និង កន្លែងបណ្ដុះបណ្ដាលវិជ្ជាជីវៈកាត់ដេរសំរាប់បណ្ដុះបណ្ដាលដល់កូនចៅប្រជាពលរដ្ឋដែលមានបំនងចង់ចេះដឹងវិជ្ជាជីវៈនេះ ។ នៅខាងជើងឆ្ងាយពីនេះបន្ដិចមានអាគារមួយ គឺជាអាគារបណ្ដុះបណ្ដាលឆ្មបជនបទ ។

ម្យ៉ាងទៀត ភូមិអន្លង់រមៀតធ្លាប់មានឈ្មោះល្បីល្បាញផ្នែករាំវង់ : នៅពេលពិធីបុណ្យចូលឆ្នាំថ្មីម្ដងៗ ក្នុងភូមិមានកន្លែងរាំវង់ពី៥ ទៅ ៦កន្លែង ។ នៅតាមកន្លែងរាំវង់នីមួយៗ មានកន្លែងខ្លះមានតន្ដ្រីសម័យលេងកំដរ ។ អ្នកចាត់ចែងកន្លែងនេះបានរៀបចំពិធីលក់ផ្កាដល់បុរសទាំងអស់ដែលប្រាថ្នាចង់រាំកំសាន្ដ ។ ការលក់ផ្កានេះ គឺដើម្បីយកកំរៃទៅអោយក្រុមតន្ដ្រីសម័យ

(១) ស្ទឹងព្រែកត្នោត, (២) កៅស៊ូនេះក្រាលពីឆ្នាំ ១៩៦៩

និង ផ្លែឈ្នួលម៉ាស៊ីនភ្លើង ។ ចំនែកកន្លែងខ្លះទៀត គ្មានតន្ត្រីសម័យលេងកំដរទេ មានតែស្គរដៃមួយ រឺអាចមានឃឹម តាខេ បន្ថែមទៀត ។ កន្លែងរាំដូចនេះ អ្នកចាត់ចែងមិនលក់ផ្កាទេ តែគេដាក់ផ្ដិលដែលមានជើងពានទ្រទៅលើតុកណ្ដាលវង់សំរាប់អោយបុរស១ដែលរាំដាក់លុយកាក់តាមសទ្ធា ដើម្បីយកកំរៃទៅទិញប្រេងសំរាប់ចាក់ចង្កៀងបំភ្លឺ ។ កន្លែងរាំវង់នីមួយ១ មានស្ត្រីសំរាប់រាំពី ៥ ទៅ ៨នាក់ គឺមិនអោយលើសពីនេះទេ ។ ធ្វើយ៉ាងនេះដើម្បីងាយស្រួលក្នុងការរាំ ហើយទស្សនិកជនដែលឈរមើល ក៏មើលបានច្បាស់អ្នកដែលរាំទាំងស្ត្រី ទាំងប្រុស ។

ពេលចាប់ផ្ដើមរាំ បុរសទិញផ្កាពីកន្លែងលក់ផ្កា ហើយយកទៅជូននារីដែលខ្លួនប្រាថ្នាចង់រាំជាមួយ តែមុននឹងជូន បុរសត្រូវសំពះសូមអញ្ជើញ ។ ចំនែកនារីវិញ មុននឹងទទួលផ្កាត្រូវសំពះតបវិញទើបឡើងរាំ ។ រីឯកន្លែង ដែលមិនលក់ផ្កាក៏គេធ្វើរបៀបនេះដែរ ប៉ុន្តែគ្រាន់តែមិនបានជូនផ្កាប៉ុណ្ណោះ តែមានបទខ្លះនារីឡើងរាំមុនបុរស ហើយបុរសដែលឈរនៅជុំវិញវង់ ត្រូវបាននារីសំពះអញ្ជើញឡើងរាំជាមួយ ពេលនារីសំពះអញ្ជើញឡើងរាំ បុរសសំពះតបវិញទើបឡើងរាំ។

ប្រវត្តិភូមិអន្លង់រមៀតតាមការនិយាយត១គ្នាថា : ដើមឡើយទីតាំងភូមិអន្លង់រមៀត ក៏ដូចជាផ្ទៃដីនៃព្រះរាជាណាចក្រកម្ពុជាយើងសុទ្ធសឹងជាផ្ទៃសមុទ្រ ។ ហេតុដូចនេះ តាមចន្លោះផ្ទៃនៃភូមិអន្លង់រមៀតនេះតែងតែមានសំពៅអ្នកជំនួញធ្វើដំនើរឆ្លងកាត់ជាប្រចាំ ។ នាថ្ងៃមួយ មានសំពៅដឹកម្សៅរមៀតមួយបានធ្វើដំនើរឆ្លងកាត់កន្លែងនេះ ត្រូវខ្យល់ព្យុះបោកបក់អោយលិចនៅក្នុងអន្លង់ដ៏ជ្រៅដែលជាទីតាំងនៅភាគឥសាននៃព្រះវិហារវត្តអន្លង់រមៀតសព្វថ្ងៃ ហើយមុនឆ្នាំ ១៩៧០ ទីតាំងនេះជាស្រះទឹកក្នុងបរិវេណវត្តអន្លង់រមៀត ។ ដោយការលិចលង់នៃសំពៅដឹកម្សៅរមៀត ដូចនេះហើយទើបអ្នកធ្វើជំនួញតាមសំពៅក្រោយ១មកតែងតែហៅកន្លែងលិចសំពៅម្សៅរមៀតនេះថា "អន្លង់រមៀត" ប៉ុន្តែការហៅត១រហូតតាំងពីផ្ទៃទឹកមកដល់កកើតជាដីមានប្រជាពលរដ្ឋរស់នៅក៏ក្លាយទៅជាអន្លង់រមៀត ។ ម្យ៉ាងទៀត ក៏មានពាក្យដំណាលពីភាពអស្ចារ្យនៃបារមីកន្លែងលង់រមៀត និង វត្តអន្លង់រមៀតនេះដែរ ។ កាលដើមឡើយ នៅក្នុងស្រះវត្តអន្លង់រមៀតដែលជាទីកន្លែងសំពៅលិចនោះ នៅពេលថ្ងៃសីល និង ថ្ងៃពេញបូរមីសំពៅតែងតែអណ្ដែតបង្ហាញរូបលើផ្ទៃទឹកស្រះអោយឧបាសក ឧបាសិកា ឃើញគ្រប់១គ្នា ។ ចំនែករឿងចំលែកមួយទៀតដែលកើតមាននៅក្នុងសម័យអាណានិគមនិយមបារាំងដែលលោកតា លោកយាយតែងតែរៀបរាប់ប្រាប់កូន និង ចៅថា : មានបារាំងម្នាក់ចង់ដឹងពីទំហំដើមឈើទាលដែលដុះនៅក្នុងបរិវេណវត្តអន្លង់រមៀត ក៏យកដៃទៅអោបវាស់ដើមឈើទាលនោះ ស្រាប់តែបារាំងនោះមិនអាចដកដៃព្រមទាំងខ្លួនចេញពីដើមឈើទាលនោះបាន លុះត្រាតែយកភ្លេងពិណពាទ្យទៅលេងថ្វាយបារមីថែរក្សាកន្លែងនោះ ៧ បទទើបដករួច ។

ចំនែកសព្វថ្ងៃនេះ ប្រជាពលរដ្ឋនៅតំបន់នេះនៅតែមានជំនឿថា បារមីរបស់ព្រះអង្គវត្តអន្លង់រមៀតខ្លាំងពូកែដែរ ព្រោះទីតាំងវត្តអន្លង់រមៀតជាបន្ទាយរបស់ទាហានសាធារណរដ្ឋខ្មែរ ហើយជាទីសមរភូមិស៊ីសាច់ហុតឈាមរវាងទាហានខ្មែរក្រហម និង ទាហានលោកសេនាប្រមុខ លន់ នល់ និង ជាកន្លែងរងគ្រាប់បែកយន្តហោះ B52 របស់សហរដ្ឋអាមេរិច។

ដូចនេះព្រះវិហារទាំងអស់ទូទាំងស្រុកកណ្ដាលស្ទឹងត្រូវខ្ទេចខ្ទី លើកលែងតែព្រះវិហារវត្តអន្លង់រមៀតទេដែលនៅមានរូបរាងដដែល ។

លោក : **ស៊ាន់ ម៉ុនលី**
អធិការបឋមសិក្សានៃអធិការដ្ឋានអប់រំ
ក្រសួងអប់រំ យុវជន និង កីឡា




# តើអ្នកគ្រូ លោកគ្រូដឹងឬទេ ?

## ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣

- ចំនួនអាសនៈតំណាងរាស្ត្រនៅរដ្ឋសភាអាណត្តិទី ៣ ........................ ១២៣ អាសនៈ
- ចំនួនគណៈបក្សចូលរួម ........................................................ ២៣ គណៈបក្ស
- ចំនួនប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោត ................................ ៦ ៣៤១ ៨៣៤ នាក់

  ក្នុងចំនោមប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត ................................ ៦ ៧៤៩ ៨៧៦ នាក់

  គិតជាភាគរយ :............................................................... ៩៣.៩៥ %
- ចំនួនប្រជាពលរដ្ឋបានទៅបោះឆ្នោត ........................................ ៥ ១៦៨ ៣១៥ នាក់

  គិតជាភាគរយ.................................................................. ៨១.៤៩ %
- គណៈបក្សប្រជាជនកម្ពុជាទទួលបាន ........................................ ២ ៤៤៧ ២៥៩ សំលេង

  គិតជាអាសនៈមានចំនួន....................................................... ៧៣ អាសនៈ
- គណៈបក្សសម រង្ស៊ីទទួលបាន ................................................ ១ ១៣០ ៤២៣ សំលេង

  គិតជាអាសនៈមានចំនួន ...................................................... ២៤ អាសនៈ
- គណៈបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ........................................... ១ ០៧២ ៣១៣ សំលេង

  គិតជាអាសនៈមានចំនួន ...................................................... ២៦ អាសនៈ
- កាលបរិច្ឆេទនៃការបើកសភាអាណត្តិទី៣ : ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៣ ក្រោមអធិបតីភាពសម្តេច ជា ស៊ីម ព្រះរាជតំនាងដ៏ខ្ពង់ខ្ពស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅមន្ទីររដ្ឋសភា ។
- កាលបរិច្ឆេទនៃការធ្វើសច្ចាប្រណិធានចូលកាន់តំនែង : ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងព្រះបរមរាជវាំង ។

# ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ ជាមជ្ឈមណ្ឌលស្រាវជ្រាវដ៏សំខាន់របស់ប្រទេសកម្ពុជា ក្នុងវិស័យអក្សរសាស្ត្រពុទ្ធសាសនា និង អក្សរសាស្ត្រ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ខ្មែរ ។ បច្ចុប្បន្ននេះ ស្ថាប័ននេះស្ថិតនៅទល់មុខមន្ទីរពិពណ៌ទន្លេបាសាក់នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ។

ពុទ្ធសាសនបណ្ឌិត្យមានអាយុ ៨២ ឆ្នាំហើយ ត្រូវបានព្រះករុណាព្រះបាទស៊ីសុវត្ថិស្ថាបនាឡើងនាឆ្នាំ ១៩២១ ដែលមានឈ្មោះថាខេមរបណ្ណាល័យ ហើយបាននិវត្តជាបន្តបន្ទាប់ ÷

- ឆ្នាំ ១៩២៥ មានឈ្មោះថា ព្រះរាជបណ្ណាល័យ
- ពីឆ្នាំ ១៩៣០រហូតមក មានឈ្មោះពុទ្ធសាសនបណ្ឌិត្យ
- ពីឆ្នាំ ១៩៧៥ ដល់ថ្ងៃ ០៧ ខែ មករា ឆ្នាំ ១៩៧៩ ទីផ្ទុកឯកសារសមោធាននោះ ក៏ត្រូវបំផ្លាញបាត់ទាំងរូប បាត់ទាំងឈ្មោះ ព្រមទាំងធនធានមនុស្សដ៏សែនសោកស្តាយបំផុត ។

ចាប់ពីឆ្នាំ ១៩៩២ ក៏ត្រូវបានបង្កើតឡើងវិញ និង រៀបចំដំណើរការនៅក្នុងកុដិពីរនៅវត្តឧណ្ណាលោមដោយរៀបចំរចនាសម្ព័ន្ធស្ថាប័នជាថ្មី និង ចាប់ផ្តើមសកម្មភាពស្រាវជ្រាវ និង បោះពុម្ពសៀវភៅធ្លាប់មានពីមុនឡើងវិញកសាងគំរោងសាងសង់អគារសមរម្យសក្តិសមនិងតួនាទីដ៏សំខាន់នៃស្ថាប័ននោះ ។ រីឯការស្ថាបនានោះ ក៏បានសំរេចទាំងអគារ ទាំងរបង ខ្លោងទ្វារ និង បំពាក់គ្រឿងសម្ភារៈបរិក្ខារចប់សព្វគ្រប់នៅពាក់កណ្តាលឆ្នាំ ២០០២ ។

ពុទ្ធសាសនបណ្ឌិត្យនៅបានរក្សាតួនាទីសំខាន់ដែលធ្លាប់មានពីមុនៗមកដូចជា ÷

**ក- ការងារបោះពុម្ពផ្សាយ**

ទស្សនាវដ្តីកម្ពុជសុរិយាបានចេញផ្សាយនាឆ្នាំ ១៩២៦ បានផ្អាកការផ្សាយក្នុងសម័យ ប៉ុល ពត និង បានដំណើរការឡើងវិញនាឆ្នាំ ១៩៩៤ ÷

- បានបោះពុម្ពឡើងវិញនូវសៀវភៅព្រះពុទ្ធសាសនា សៀវភៅទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ និង អក្សរសាស្ត្រដែលវិទ្យាស្ថានបានចេញផ្សាយពីសម័យមុន ។

- រៀបរៀងចងក្រងទស្សនាវដ្តី"កម្ពុជសុរិយា"ជាបន្តទៀតចាប់ពីឆ្នាំ១៩៨៦ ផ្សាយចេញរៀងរាល់ត្រីមាស។

**ខ- ក្រុមជំនុំព្រះត្រៃបិដក**

គឺជាគណៈកម្មការមួយដែលបានបង្កើតឡើងនាឆ្នាំ ១៩២៩ ជាជំហានដំបូង គឺសំរាប់បកប្រែព្រះត្រៃបិដកពីភាសាបាលីមកជាខេមរភាសា ។

ចំពោះមុខនេះ ក្រុមជំនុំនេះបានបង្កើតនាទីមួយចំនួន ÷

- នាទីទ្រទ្រង់ព្រះត្រៃបិដក
- នាទីទ្រទ្រង់ព្រះពុទ្ធសាសនា

## គ. ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំនេះ គឺជាគណៈកម្មការស្រាវជ្រាវមួយដែលបង្កើតឡើងនាឆ្នាំ ១៩៣៤ ដើម្បីស្រាវជ្រាវចងក្រងប្រពៃណីទំនៀមទម្លាប់ខ្មែរ និង របស់ជនជាតិនានាតាមតំបន់ផ្សេងៗគ្នានៅទូទាំងប្រទេស ។ ដើម្បីងាយស្រួលដល់ការស្រាវជ្រាវ ក្រុមជំនុំមានសមាជិកឆ្លើយឆ្លងនៅតាមបណ្ដាខេត្តទៀតផង ។

## ឃ. បណ្ណាល័យ

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យកើតឡើងក្នុងឆ្នាំ ១៩២៥ ដែលក្នុងសម័យមុនមានឯកសារប្រមាណជាង ៤ម៉ឺនចំណងជើង ហើយបច្ចុប្បន្នមានសៀវភៅចំនួន ១១.៧១៤ ក្បាល ក្នុងនោះភាសាខ្មែរចំនួន ៧.៦៩៩ និង ភាសាបរទេសចំនួន ៤.០១៥ក្បាល ជាប្រភេទសៀវភៅវប្បធម៌សាសនា អក្សរសាស្ត្រ និង ប្រវត្តិសាស្ត្រ ។

ក្រៅពីបណ្ណាល័យធំនៅភ្នំពេញ នៅមានបណ្ណាល័យសាខាចំនួន ១៨ នៅតាមខេត្ត-ក្រុងទៀតផង ។

ពុទ្ធសាសនបណ្ឌិត្យ បានបំពេញបេសកម្មដ៏ល្បីល្បាញក្នុងការបំរើវិស័យអក្សរសាស្ត្រពុទ្ធសាសនា និង អក្សរសាស្ត្រ វប្បធម៌ ប្រពៃណី និង ទំនៀមទម្លាប់ខ្មែរជិតមួយសតវត្សមកហើយ ។



ខ្លោងទ្វារខាងជើង

**កែវ យ៉ារ**

៚ ✥ ៚

# សិទ្ធិស្ត្រី

## ស្ត្រីក្នុងវិស័យច្បាប់



នារីមានសិទ្ធិគ្រប់ករណីទាំងអស់ ក្នុងការប្តឹងទាមទារអោយមានការការពារសិទ្ធិសេរីភាពទៅតុលាការគ្រប់ជាន់ថ្នាក់ និង ទៅគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឬក៏អាចធ្វើបណ្តឹងនេះឡើងតាមរយៈអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាល នៅពេលដែលបានដឹងថាសិទ្ធិ និង សេរីភាពរបស់ខ្លួនត្រូវបានទទួលការរំលោភបំពាន ។

**ច្បាប់រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញកម្ពុជាមាត្រា ៣១ ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់..." ។ មាត្រា ៤៥ ចែងថា "ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល" ។ គ្រប់កថាខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៤, ៣៥, ៣៦, ៤៣, ៥០ ដែលនិយាយពីសិទ្ធិបោះឆ្នោត ឈរឈ្មោះបោះឆ្នោត ចូលរួមក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ជ្រើសរើសមុខរបរ ជំនឿសាសនា សិទ្ធិបង្កើតសហជីពជាដើម សុទ្ធតែសរសេរថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ" បើកសិទ្ធិ និង ផ្តល់សេរីភាពដូចៗគ្នា ។ មាត្រា ៣៦-៣ ចែងថា "ការងារមេផ្ទះមានតំលៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ" ។ ដូចនេះមានន័យច្បាស់ណាស់ថា បុរស និង នារីគឺមាន សិទ្ធិស្មើគ្នា ។

**ច្បាប់ព្រហ្មទណ្ឌ**

ច្បាប់ព្រហ្មទណ្ឌអន្តរកាលក៏បានកំណត់បទល្មើសទាំងឡាយដែលជាអំពើរើសអើងចំពោះនារីភេទរួមមានបទល្មើសរំលោភសេពសន្ថវៈ (មាត្រា ៣៣) អំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ (មាត្រា ៤២) ។ ឧទាហរណ៍ : ប្តីដែលចាប់បង្ខំប្រពន្ធរួមរក្សដោយប្រពន្ធមិនព្រមក៏ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ដូចបង្ខំជនដែលគ្មានចំនងអាពាហ៍ពិពាហ៍ដូច្នោះដែរ ។ ដូចនេះឃើញថា ច្បាប់នៅកម្ពុជាការពារស្ត្រីភេទច្រើន ។

**ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ**

បញ្ហាពាក់ព័ន្ធនឹងគ្រួសារ ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ សិទ្ធិស្ត្រីត្រូវបានការពារគ្រប់គ្រាន់ ។ ឧទាហរណ៍ដូចជាមាត្រាខ្លះចែងថា :

- មាត្រា ២៩ "ក្នុងគ្រួសារ ប្តី និង ប្រពន្ធត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ" ។
- មាត្រា ៣២ " ប្រពន្ធ ប្តីមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ការអាស្រ័យផល ការចាត់ចែងទ្រព្យសម្បត្តិរួម" ។
- មាត្រា ៤០ "ប្តី ប្រពន្ធ អាចលែងលះគ្នាដោយស្ម័គ្រចិត្តបាន" ។
- មាត្រា ៧៤ "ឪពុកម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយអប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន" ...។

**ច្បាប់ភូមិបាល**

ទាក់ទងទៅនឹងសិទ្ធិមានកម្មសិទ្ធិលើដីធ្លី ច្បាប់រដ្ឋធម្មនុញ្ញមាត្រា ៤៤ ចែងថា "ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ" ខុសពីប្រទេសខ្លះដែលច្បាប់បានហាមប្រាមទៅលើស្ត្រីថា មិនអោយសិទ្ធិកម្មសិទ្ធិលើដីធ្លីណាមួយឡើយ ។

**ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស**

មាត្រា ២ នៃច្បាប់ខាងលើចែងថា "ត្រូវហាមឃាត់ដាច់ខាត អំពើពង្រត់មនុស្សយកទៅលក់ដូរ ឬយកទៅធ្វើពេស្យាចារ និង អំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុង ឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។ ថ្មីៗនេះ ក្រសួងយុត្តិធម៌ក៏បានធ្វើសេចក្តីព្រាងច្បាប់ថ្មីមួយទៀត ដោយសារការអនុវត្តច្បាប់ចាស់មិនសូវមានប្រសិទ្ធិភាព និង មានបញ្ហាក់ន័យអោយបានច្បាស់ ។ ជាគោលការណ៍ ការធ្វើសេចក្តីព្រាងច្បាប់ថ្មី គឺក្នុងគោលបំណងដើម្បីការពារជនរងគ្រោះ ជាពិសេសជនរងគ្រោះ ដែលជានារី និង កុមារ ។

**ច្បាប់ការងារ**

មាត្រា ១៨២ នៃច្បាប់ការងារចែងថា "ក្នុងសហគ្រាសទាំងអស់ ... ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាកកៅសិបថ្ងៃ ដើម្បីសំរាលកូន ។ ក្រោយពីឈប់សំរាលកូនក្នុងរយៈពេលពីរខែដែលបានចូលធ្វើការត្រូវអោយស្ត្រីនោះធ្វើការតែការងារណាស្រាលៗ ។ ត្រូវហាមឃាត់មិនអោយនិយោកជកបញ្ឈប់ស្ត្រីសម្រាលកូននៅពេលឈប់ឆ្លងទន្លេ ឬនៅថ្ងៃណាមួយក្នុងពេលឈប់សំរាលកូននេះ ទោះដោយវិធីអោយដំណឹងមុនក៏ដោយ" ។ ក្រៅពីនោះមាត្រា ៨៣, ១៨៤, ១៨៥, ១៨៦ ក៏បានចែងពីការអនុគ្រោះយ៉ាងច្រើនដល់និយោជិតជាស្ត្រីដែរ ។

**ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល**

មាត្រា ៩១ ស្តីពីច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ចែងថា "បេក្ខជនទាំងពីរភេទអាចទទួលអោយចូលធ្វើការ ក្នុងក្របខណ្ឌរាជការបាន..." ។

ដូចនេះ បច្ចុប្បន្នប្រទេសកម្ពុជាយើង បាននិងកំពុងអនុវត្តច្បាប់ដោយលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទជាបណ្តើរៗ គួរជាទីមោទនៈ ទោះបីជាការអនុវត្តច្បាប់ខាងលើពុំទាន់បានល្អគ្រប់ជ្រុងជ្រោយក្តី។

**ហួរ សារី**

"ការរើសអើងប្រឆាំងលើស្ត្រីភេទ គឺជាការរំលោភទៅលើគោលការណ៍នៃសិទ្ធិស្មើគ្នា និង គោលការណ៍ស្តីពីការគោរពចំពោះភាពថ្លៃថ្នូររបស់មនុស្ស ៗ

# ស្ថានភាពអប់រំ មត្តេយ្យ និងចំនេះទូទៅ គ្រឹះស្ថានសាធារណៈ ឆ្នាំសិក្សា ២០០២-០៣

## សង្ខេបៈ

នៅឆ្នាំសិក្សា២០០២-០៣ សរុបសាលារៀនទាំងអស់មាន ៧.៦៥៤ ចែកជាមត្តេយ្យសិក្សា ១.១៤៥ បឋមសិក្សា ៥.៩១៥ (សាលាបឋមសិក្សាគ្រប់គំរិតថ្នាក់ចំនួន ៥៩.៥%) អនុវិទ្យាល័យ ៤១១ និង វិទ្យាល័យ ១៨៣។ សរុបថ្នាក់រៀនគ្រប់គំរិតសិក្សា ៧៣.៤៥៨ ក្នុងនេះមត្តេយ្យសិក្សាមាន ២.០៤១ បឋមសិក្សា ៥៩.៨៩៧ មធ្យមសិក្សាបឋមភូមិ ៨.៧៩៩ និងមធ្យមសិក្សាទុតិយភូមិ ២.៧២១។ សិស្សសរុបទូទាំងប្រទេសមាន ៣.៣៥៦.០២៣ ( ស្រី ៤៥.៨៥%) ដែលចែកជាមត្តេយ្យ ៦៤.៧២៧ ( ស្រី ៤៩.៨២%) បឋមសិក្សា ២.៧៤៧.៤១១ ( ស្រី ៤៦.៧៣%) មធ្យមសិក្សាបឋមភូមិ ៤១៥.៧០៣ ( ស្រី ៤០.០៧%) និងមធ្យមសិក្សាទុតិយភូមិ ១២៨.១៨២ ( ស្រី ៣៣.៣៩%)។ ក្នុងចំនួនសិស្សសរុបទាំងអស់នេះ មានសិស្សត្រួតថ្នាក់ ៩.៣៨% ( ស្រី ៨.៤៨% ប្រុស ១០.១៣%)។ បុគ្គលិកនៅក្នុងគ្រឹះស្ថានសិក្សា មត្តេយ្យ និងចំនេះទូទៅសាធារណៈសរុបមាន ៨៥.៥២៦ ( ស្រី ៣៦.៨%) ដែលចែកជាបុគ្គលិកបង្រៀនសរុប ៧៣.៦៤២ ស្មើនឹង ៨៦.១% នៃបុគ្គលិកសរុប និងបុគ្គលិកមិនបង្រៀន ១៣.៩%។ បុគ្គលិកបង្រៀននៅមត្តេយ្យសិក្សាមាន ២.៣៧៩ ( ស្រី ៩៩.១២%) បឋមសិក្សាមាន ៤៨.៤៣៣ ( ស្រី ៤០.១៨% ដោយឡែកភ្នំពេញមាន ៧២.៧៧%) មធ្យមសិក្សា បឋមភូមិ១៧.៤២៣ ( ស្រី ៣២.៥៣%) និងមធ្យមសិក្សាទុតិយភូមិ ៥.៤០៧ ( ស្រី ២៤.៦២%)។

អាំងឌីកាទ័រសំខាន់ៗ ក្នុងឆ្នាំសិក្សានេះគឺ ផលធៀបសិស្ស-គ្រូទូទាំងប្រទេស ៤៥.៦ នៅតំបន់ក្រុង ៣៣.២ តំបន់ជនបទ ៤៩.៨ និងតំបន់ដាច់ស្រយាល ៥៩.៦។ បើគិតតាមប្រភេទសាលារៀនវិញ មត្តេយ្យសិក្សាមាន ២៧.២ បឋមសិក្សា ៥៦.៧ អនុវិទ្យាល័យ ២៣.៥ ( មធ្យមសិក្សាបឋមភូមិ ២៣.៩) និងវិទ្យាល័យ ២៤.១ ( មធ្យមសិក្សាទុតិយភូមិ ២៣.៧)។ ផលធៀបសិស្ស-ថ្នាក់ទូទាំងប្រទេស ៤៥.៧ នៅមត្តេយ្យសិក្សា ៣១.៧ បឋមសិក្សា ៤៥.៩ អនុវិទ្យាល័យ ៤៥.៨ និងវិទ្យាល័យ ៤៨.២។ ផលធៀបសិស្ស-បន្ទប់រៀនទូទាំងប្រទេសមាន ៦៥.៨ នៅតំបន់ក្រុង ៧១.២ តំបន់ជនបទ ៦៥.១ និងតំបន់ដាច់ស្រយាល ៥៣.៦ បើគិតតាមប្រភេទសាលារៀន នៅមត្តេយ្យសិក្សាមាន ៣៤.២ បឋមសិក្សា ៦៩.២ អនុវិទ្យាល័យ ៥២.២ និងវិទ្យាល័យ ៦២.៧។ ចំពោះផលធៀបគ្រូ-ថ្នាក់រៀនទូទាំងប្រទេសមាន ១,០០២ តំបន់ក្រុង ១,៣៤ តំបន់ជនបទ ០,៩៣ តំបន់ដាច់ស្រយាល ០,៦៤។ បើគិតតាមប្រភេទសាលារៀន ផលធៀបគ្រូ-ថ្នាក់រៀន មត្តេយ្យសិក្សាមាន ១,១៧ បឋមសិក្សា ០,៨១ (បើបញ្ចូលគ្រូជាប់កិច្ចសន្យា-គ្រូសហគមន៍ និងព្រះសង្ឃជួយបង្រៀនផលធៀបនេះកើនមក០,៨៣) មធ្យមសិក្សាបឋមភូមិ ១,៩៨ និង មធ្យមសិក្សាទុតិយភូមិ ១,៩៩។ ក្នុងនោះ ការប្រមូលសិស្សចូលរៀន អត្រារួមចូលរៀនថ្មីថ្នាក់ទី១មាន ១៣៤.៤ ( ស្រី ១២៧.៣) អត្រាពិត ៧៨.១ ( ស្រី ៧៥.៧)។ អត្រារួមនៃការសិក្សានៅបឋមសិក្សាមាន ១១៨.០ ( ស្រី ១១២.០) មធ្យមសិក្សាបឋមភូមិ ៣៦.៥ ( ស្រី ២៩.៥) និងមធ្យមសិក្សាទុតិយភូមិ ១១.៩ ( ស្រី ៧.៩)។ ចំពោះអត្រាពិតនៃការសិក្សានៅបឋមសិក្សាមាន ៨៨.៩ ( ស្រី ៨៦.៨) មធ្យមសិក្សាបឋមភូមិ ១៩.១ ( ស្រី ១៧.១) និងមធ្យមសិក្សាទុតិយភូមិ ៦.៧ ( ស្រី ៥.២)។ អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិមាន ៨៣.២ ( ស្រី៧៩.១) និងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិគឺ ៥៩.២ ( ស្រី៦២.៨)។

គុយ ផល្លា

ក្រសួងអប់រំ យុវជន និងកីឡា

# ស្ត្រីខ្មែរកាលពី ១០០ឆ្នាំមុន










ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤

រោងពុម្ព ឥន្ទ្រីយ៍មាស